# តើអ្នកជឿការនេះដែរឬទេ?

ហើយមុនយើងអធិស្ឋាន ខ្ញុំចង់និយាយការនេះ នៅល្ងាចថ្ងៃមុន ខ្ញុំជឿថា វា ដូច្នេះ ខ្ញុំបាននិយាយទៅកាន់ស្ត្រីម្នាក់ "ប្រសិនបើអ្នកធ្វើតាម ការណែនាំរបស់យើងថាវាអាច...គឺក្មេងដែលមានជំងឺទឹកក្បាល(waterhead) បានរួមទៅ។" ហើយក្បាលរបស់ក្មេងបានរួមទៅ យប់មិញគឺមួយអីញកន្លះវាស់ដោយខ្សែ។ ដូច្នេះ ស្ត្រីក៏បាននាំវាមកទីនេះ។

2 ឥឡូវនេះ បងស្រី ហេតុផលដែលខ្ញុំបានធ្វើដូច្នេះ គឺខ្ញុំមានគោលបំណង។ ឃើញទេ? ប្រសិនបើអ្នកឃើញអ្វីមួយកើតឡើងជាក់ស្ដែង ធ្វើឱ្យអ្នកមានជំនឿលើវា។ ពេលខ្លះ ខ្ញុំធ្វើដូច្នេះគឺគ្រាន់តែ ដូចជាដាស់មនុស្សឲ្យ ក្រោកពីដំណេក ដើរមួយឬពីជំហាន ពត់ដៃ បត់ម្រាមដៃ ជាអ្វីដែលពួកគេអាចធ្វើខុសគ្នា គឺគ្រាន់តែដើម្បីឲ្យគេមើលឃើញថាទាំងអស់ត្រឹមត្រូវ។ គេវិលវុល និងគិតថាវាមិនកើតឡើង ប៉ុន្តែវាកើតឡើងគ្រប់ពេលវេលា។ ឃើញទេ? គឺវាកើតឡើង។

3 តើប៉ុន្មានអ្នកចង់អធិស្ឋានឥឡូវនេះ? តើអ្នកអាចលើកដៃ និងនិយាយថា "ឱព្រះអម្ចាស់អើយ សូមទទួលយក?" សូមយើងទាំងអស់គ្នាឱនក្បាលចុះ។

4 ព្រះអម្ចាស់អើយ នៅពេលដែលយើងបានឮបទចម្រៀងនេះនៅក្នុងក្រុមជំនុំ ដែលសរសេរឡើងដោយសម្លាញ់ Paul Rader ចំណងជើងថា "គ្រាន់តែជឿតាម" ឥឡូវនេះយើងគិតអំពីក្មេងប្រុសម្នាក់ ដែលឪពុករបស់គេបាននាំមកឯសាវ័កមិន លើសពីដប់ថ្ងៃ ដែលព្រះយេស៊ូវប្រទានអំណាចដល់គេ ក្នុងការបណ្ដេញវិញ្ញាណ អាក្រក់ និងព្យាបាលអ្នកជំងឺ ហើយនៅត្រង់នេះគេបានទទួលជ័យជម្នះលើករណីជំងឺឆ្កួតជ្រូក។ ហើយ ពួកគេបានឃើញពីការយាងមកដល់នៃព្រះអម្ចាស់នៃយើង។ ហើយឪពុកក៏រត់មក ហើយនិយាយថា "ព្រះអម្ចាស់អើយ សូមសម្ដែងសេចក្ដីអាណិតមេត្តាដល់ទូលបង្គំផង។ កូនប្រុសរបស់ទូលបង្គំ ត្រូវបានរុកគួនដោយ វិញ្ញាណអាក្រក់។ ខ្ញុំបាននាំគេទៅឯសាវ័ករបស់ទ្រង់ ហើយគេមិនអាចព្យាបាល កូនប្រុសកូនបានទេ។"

5 ព្រះយេស៊ូមាន ព្រះបន្ទូលថា "ខ្ញុំអាច ប្រសិនបើអ្នកជឿតាម។ គ្រាន់តែជឿតាម។" ឱព្រះអង្គអើយ ទ្រង់មិនដែលប្រែប្រួលឡើយតាំងពីដើមរៀងមក ព្រះអង្គ

មានក្តីស្រឡាញ់ភាពផ្អែមល្ហែមនិងសេចក្តីអាណិតមេត្តារបស់ព្រះអង្គនៅដដែល។ ដោយសារព្រះអង្គមានទាំងអស់នេះ ដូច្នេះថ្ងៃនេះព្រះអង្គសព្វព្រះទ័យ ធ្វើការនេះដដែល។ ហើយ ឱព្រះអម្ចាស់អើយ ដូចជាឪពុកម្នាក់នេះដែរ យើងទាំងអស់គ្នាយំ "ព្រះអម្ចាស់អើយ ជួយដល់អ្នកដែលមិនជឿ។" វាគឺជារឿងសមញ្ញ យើងគ្រាន់តែលុតជង្គង់នៅចំពោះព្រះបិតា។

6 យើងចង់ថ្វាយការអរព្រះគុណ នឹងការសរសើរសម្រាប់ការប៉ះពាល់ ដល់ក្មេងម្នាក់នោះកាលពីយប់មិញ ដើម្បីឃើញពីលលាដ៍ក្បាល ដែលបានហើម នោះគឺនោះគឺជាឆ្អឹងដែលបានចេញមកក្រៅ វាបានធ្លាក់ចុះមកមួយអ៊ីង កន្លះកាលពីយប់មិញ។ ពួកយើងពេញដោយក្តីអំណរសម្រាប់ការនោះ ដល់ព្រះវរបិតា។ នៅពេលយើងដឹងថា គ្រូពេទ្យរបស់យើងមិនអាចស្វែងរកការព្យាបាលជំងឺនេះបានគ្មានអ្វីដែលពួកគេអាចធ្វើបាននោះទេ ប៉ុន្តែការនោះមានតែព្រះទេ ជាព្រះនៃគ្រប់ការទាំងអស់។ យើងសូមអរព្រះគុណព្រះវរបិតា។ យើងសូមអរព្រះគុណព្រះបិតាសម្រាប់ភាពស្មោះត្រង់ ហើយនឹងភាពផ្អែមល្ហែមនឹងការគោរពរបស់ ម្តាយគាត់ដើម្បីនាំយកមក វិញនូវខ្សែនឹងបិទវានៅលើក្រដាសនេះ នៅទីនេះដើម្បីបង្ហាញពីទីបន្ទាល់របស់គាត់ ទៅកាន់មនុស្សទាំងអស់ពីសិរីរុងរឿងរបស់ព្រះ។ សូមឲ្យកូនរបស់គាត់អាចរស់នៅ នឹងក្លាយជាក្មេងធម្មតាម្នាក់ សម្រាប់សិរីល្អរបស់ទ្រង់។

7 សូមមើលដៃមនុស្សទាំងអស់បាន លើកឡើងទៅកាន់ព្រះវរបិតា។ ពួកគេម្នាក់ៗសុទ្ធតែមានតម្រូវការ។ ថ្វាយរបស់ទាំងអស់ទៅកាន់ព្រះវរបិតាផងដែរ ខ្ញុំមានតម្រូវការ។ ហើយតម្រូវការទាំងនោះគឺនៅទីនេះហើយ ជាទម្រង់សំបុត្រ ឬក៏នៅក្នុងប្រអប់នេះ នោះគឺជាតម្រូវការ របស់មនុស្សដែលពិតជាមានតម្រូវការខ្លាំង។ សូមឲ្យការនេះបានសម្រេច ព្រះជាម្ចាស់ ដែលគ្រប់គ្នានឹងទទួលបានតាមការអធិស្ឋាននៅយប់នេះ។ សូមឲ្យពួកគេនាំយកទីបន្ទាប់របស់ម្តាយម្នាក់នេះ នឹងជា គំរូសម្រាប់ពួកគេម្នាក់ៗ ដើម្បីបង្ហាញថា នៅពេលដែលទ្រង់មានបន្ទូលអ្វីមួយ វាត្រូវតែសម្រេច។ វាគឺជា...ទ្រង់...អ្វីទាំងអស់ដែលយើងធ្វើគឺគ្រាន់តែទទួលវា នឹងធ្វើតាម។ នោះគឺជាការចប់សព្វគ្រប់ហើយ។

8 សូមប្រទានឲ្យ ឱព្រះជាម្ចាស់ ទៅកាន់សំបុត្រនីមួយៗ ហើយនឹងពាក្យនៅលើកន្សែងដៃទាំងនេះ មនុស្សទាំង អស់ដែលបានក្រាបចុះ ពួកគេនឹងទទួលបានការព្យាបាល។ គ្រប់គ្នាដែលបានលើកដៃរបស់ពួកគេ ឱព្រះវរបិតា ពួកគេអាច នឹង

ទទួលតាមបំណង ចិត្តរបស់ ពួកគេ...យើងទូលសូមនៅក្នុងព្រះនាមព្រះយេស៊ូ។ អាម៉ែន។ សូមអញ្ជើញអង្គុយចុះ។

9 ខ្ញុំគ្រាន់តែចង់បង្ហាញដល់អ្នកទាំងអស់គ្នាពីខ្សែនៅទីនេះ ដែលស្ត្រីនោះបាន...នោះហើយគឺជាខ្សែ។ អឺម។ នោះគឺជាខ្សែបង្រួញក្បាលក្មេងប្រុសម្នាក់នោះ ដូចដែលព្រះបានសន្យាដល់យើង តាមរយៈព្រះវិញ្ញាណបរិសុទ្ធកាលពីយប់មិញ។ តើទ្រង់ពិតជាអស្ចារ្យទេ? ដូច្នេះហើយ ការនេះបានផ្តល់ការលើកទឹកចិត្តយ៉ាងខ្លាំង ដល់យើង ដើម្បីមានជំនឿ នឹងជឿលើទ្រង់។

10 ឥឡូវ នៅពេលព្រះយេស៊ូបានមានបន្ទូល ទៅកាន់ដើមឈើនោះ នៅក្នុងម៉ាកុសជំពូកទី 11:23 "គ្មានមនុស្សណាម្នាក់ អាចបរិភោគ ចាប់តាំង ពីពេល នេះតទៅ" គាត់ប្រហែលជាមិនអាចបង្កើតផលផ្លែបានទេ។ ហេតុអ្វីដូចជា មិនមានការលាក់លៀមសោះ ទ្រង់ដូចជាងាយស្រួលជាមួយនិងការនេះ រហូត ទាល់តែសាវ័ករបស់ទ្រង់ គ្រាន់តែ...ខ្ញុំគិតថា មានម្នាក់ក្នុងចំណោមពួកគេបានឮពីទ្រង់។ ហើយវា...នៅពេលដែលជំងឺស្កន់នោះ ពេលវាបានមកចំពោះព្រះយេស៊ូ ក្មេងប្រុសនោះមានសុខភាពធ្ងន់ធ្ងរដែលគាត់មិនធ្លាប់មានពីមុនមក ប្រហែលជាគាត់អាចនិងដួលចុះមកក្រោមដូចជាបានស្លាប់ហើយ ប៉ុន្តែគាត់បានដឹងច្បាស់ថា គាត់បានជួបមនុស្សម្នាក់ ជាអ្នកដែលមានមានជំនឿ លើសពីពួកសាវ័កទៅទៀត។

11 ឥឡូវ ខ្ញុំចង់ឲ្យអ្នកអត់ជឿទៅលើការព្យាបាល ពីព្រះមើលពីការនេះ។ ព្រះយេស៊ូបានប្រទានអំណាចដល់ពួកគេ ដើម្បីដេញ វិញ្ញាណអាក្រក់ចេញ ហើយពួកគេបានបរាជ័យ។ មិនមែនអំណាចចុះចាញ់ នោះទេ ប៉ុន្តែពួកគេបានចុះចាញ់។ គេបានបរាជ័យ...ព្រះយេស៊ូ បានមានបន្ទូល ទៅកាន់ ពួកគេ...

"ហេតុអ្វីបានជាយើងខ្ញុំពុំអាចដេញអារក្សនោះបាន"

ទ្រង់មានបន្ទូលថា "មកពីការមិនជឿរបស់អ្នក។"

12 ក្រុមជំនុំនៅតែមានអំណាច។ ព្រះជាម្ចាស់មិនដែលដក យកអំណាចចេញពីពួកជំនុំឡើយប៉ុន្តែក្រុមជំនុំដែលមិនមានជំនឿគ្រប់គ្រាន់ក្នុងការទទួលវា។ គឺតែប៉ុណ្ណឹង។ វាគឺគ្រាន់តែជាការធម្មតាប៉ុណ្ណោះ។ ពេលខ្លះយើងព្យាយាមធ្វើឲ្យវាមានការស្មុកស្មាញ ប៉ុន្តែកាលណាអ្នកធ្វើឲ្យដំណឹងល្អ កាន់តែធម្មតានោះកាន់តែការពិតនូវអ្វីដែលអ្នកមាន នៅពេលដែលអ្នកធ្វើឲ្យទៅជាធម្មតាពិត: ព្រះមាន

បន្ទូលដូច្នេះនោះហើយជាដំណោះស្រាយគឺតែប៉ុណ្ណឹង។ គឺគ្រាន់តែជឿហើយបន្ត។

13 នៅពេលព្រះយេស៊ូ បានមានបន្ទូលថា "ចាប់ពីពេលនេះតទៅគ្មាននរណា បរិភោគផ្លែរបស់ឯងទៀតឡើយ" ហេតុអ្វីបានជាស្លឹកវាស្អាត និងមានពន្លឺដូចដែលពួកវាមានដូច្នេះ។ សំបករបស់វានៅដដែល ប៉ុន្តែវាទម្រេតនៅក្បែរឫសនៅក្នុងដីជីវិតរបស់វាចាប់ផ្ដើមថយចុះបន្តិចម្ដងបន្តិចម្ដង។

14 ដូច្នេះហើយ វាស្ថិតនៅលើជំងឺមហារីក ស្ថិតនៅលើប្រភេទនៃជំងឺដែល—អ្នកអាចនិងគិតដល់។ នៅពេលអ្នកអាចទទួលយកព្រះបន្ទូលរបស់ព្រះជា ម្ចាស់ ចាក់ចូលទៅក្នុងឫសកាន់តែជ្រៅ ជំងឺមហារីកអាចមាននៅទីនោះ ដៃរបស់អ្នកអាចរឹងឡើង។ ដែលមិនមានអ្វីត្រូវធ្វើជាមួយនឹងការ ព្យាបាលដោយភាពជាព្រះនោះទេ។ វាជា "ប្រសិនបើអ្នកអាចជឿបាន។" ឃើញទេ? ដាក់ខ្លួនក្នុងការធ្វើអ្វី វាគឺបានសម្រេចការនោះរួចទៅហើយ។

15 ព្រះយេស៊ូ មានបន្ទូលថា "បើអ្នករាល់គ្នាពោលទៅកាន់ភ្នំនេះថាៈ 'ចូររើចេញ'ដោយគ្មានការសង្ស័យប៉ុន្តែជឿថាអ្វីដែលអ្នកនិយាយនឹងអាចសម្រេចបាន អ្នកអាចមាននូវអ្វីដែលអ្នកនិយាយ។" តើវាពិតជាអស្ចារ្យទេ? តើអង្គនោះយាងមកពីណា? គឺជាព្រះរាជបុត្រានៃព្រះ ព្រះបន្ទូលអ្នកណា...ផ្ទៃមេឃ និងផែនដីនឹងរលាយបាត់ទៅ ប៉ុន្តែឥឡូវ—តែព្រះបន្ទូលរបស់ទ្រង់មិនរលាយបាត់ទេ។

16 ឥឡូវ មានវិធីមួយដែលអ្នកអាចធ្វើដូច្នោះបាន អ្នកត្រូវតែមានគោលដៅត្រឹមត្រូវនិងការជំរុញត្រឹមត្រូវ។ ពេលនេះប្រសិនបើខ្ញុំចេញមក ទីនេះ ហើយនិយាយថា "ខ្ញុំនឹងបង្ហាញអ្នកថាខ្ញុំអាចរើភ្នំនេះចេញបាន 'ចូររើចេញទៅភ្នំ'" វាពិតជាមិនរើ ចេញឡើយ។ ពិតជាមិនរើចេញឡើយ។ មិនថាវិធីអ្វីដែលខ្ញុំបានធ្វើ។ វាត្រូវតែ...ជាដំបូងអ្នកត្រូវតែយល់ពីបំណងព្រះហឫទ័យរបស់ ព្រះជាម្ចាស់។

17 នោះហើយ គឺជាមូលហេតុទូទៅនៅក្នុងការអធិស្ឋាន ខ្ញុំ—ខ្ញុំស្ថិតនៅក្នុងស្ថានភាពដ៏លំបាកបំផុតគឺព្រោះតែមានអ្វីមួយដែលបានឆ្លងកាត់តាមរយៈ ការអធិស្ឋាន និងជាច្រើនទៀត ហើយនឹង នោះគឺជាកន្លែងដែលអ្នកបានទទួលត្រឡប់ មកវិញ។ ប៉ុន្តែឃើញទេប្រសិនបើ អ្នកមិនបានសារភាពបាបទេ...តើអ្នកធ្លាប់បានកត់ចំណាំលើករណីមុនពេលខ្ញុំអធិស្ឋានឲ្យវិញ្ញាណអាក្រក់ចេញទៅទេ? ខ្ញុំបានមើលពីករណីពិតនោះយ៉ាងជាក់លាក់ដើម្បីប្រាកដថាមិនមានអ្វីមួយនៅក្នុង

ជីវិតនោះដែលរារាំងឡើយឃើញទេ ដោយព្រោះការចងចាំទៅលើអំណោយទានទាំងនេះ អ្នកអាចមានបញ្ហាជាមួយនឹងពួកវា។

18 ព្រះជាម្ចាស់ អ្នកចាំបានទេថាមានពេលមួយបានឲ្យហោរា...ធ្វើឲ្យមាន ហោរាចេញពីមនុស្ស លោកម៉ូសេ ហើយបានប្រាប់គាត់ឲ្យចុះមក និយាយទៅកាន់ថ្ម។ ហើយហោរាបានរំភើប ហើយក៏ចេញទៅវាយថ្មនោះ និយាយពីភាពខ្សោយរបស់ព្រះគ្រិស្ត ដែលទ្រង់បានសុគតជាលើកទីពីរ ឬក៏ត្រូវបានវាយជាលើក ទីពីរ។ ទ្រង់មានអំណាចទៅលើវា ប៉ុន្តែនោះ មិនមែនជាបំណងព្រះហឫទ័យរបស់ព្រះឡើយ។

19 ខ្ញុំមិនធ្លាប់ជឿថានោះ គឺជាបំណងរបស់ព្រះសម្រាប់លោក អេលីសេដើម្បី ទៅជុំវិញនោះ បង្កឲ្យកូនក្មេងបានលេងសើចដាក់គាត់អំពីក្បាលទំពែក ខ្ញុំគិតថា គាត់មិនគួរណាធ្វើរឿងបែបនោះឡើយ។ ប៉ុន្តែគាត់គឺជាព្យាការីម្នាក់ ហើយគាត់ក៏ បានខឹង ហើយគាត់បានដាក់បណ្តាសារទៅលើក្មេងទាំងនោះ និងនាងអត់ទ្រាំ ជាមួយនិងការសម្លាប់ក្មេងដែលគ្មានកំហុសចំនួនសែសិបពីរនាក់។ ឃើញទេ? ប៉ុន្តែខ្ញុំមិនជឿថាគាត់បានធ្វើរឿងដូច្នោះទេ។ ហើយ វាគ្រាន់តែ—គ្រាន់តែ...យើង...

20 ព្រះជាម្ចាស់ ខ្ញុំជឿថាថ្ងៃនេះ មុនពេលដែលទ្រង់បានប្រទានអំណាចដល់អ្នកជឿ ទ្រង់ព្យាយាមឲ្យ អ្នកដែលជឿលើទ្រង់ ឃើញពីអ្វីដែលនឹងកើតមានឡើង។

21 យើង...ពេលក្រោយ ប្រហែល ប្រសិនបើនេះជាបំណងព្រះហឫទ័យរបស់ ព្រះនៅពេលខ្ញុំត្រឡប់មកវិញ យើងនិងមានពេលស្នាក់នៅដូចនោះ ទៅលើអ្វី ដែលបានកំណត់ឲ្យកើតឡើង បន្ទាប់មក យើងនិង ដឹងពីការនោះបន្ថែមទៀត។

22 ប៉ុន្តែ ប្រសិនបើ អ្នកគ្រាន់តែនិយាយពីព្រះបន្ទូលថា "ព្រះជាម្ចាស់ ខ្ញុំជឿពីការនេះ" កុំសង្ស័យ មានន័យថាជឿដោយអស់ពីចិត្តរបស់អ្នក...

23 ឥឡូវនេះ ឧទាហរណ៍ អ្នកនិយាយថា ខ្ញុំស្ថិតនៅក្នុងជ្រលងភ្នំ ហើយខ្ញុំមិន... ខ្ញុំកំពុងតែអធិប្បាយទៅកាន់មនុស្សមួយលាននាក់ ប៉ុន្តែគ្រាន់តែឆ្លងកាត់ភ្នំ នេះគឺមានមនុស្សមួយរយនាក់ ដែលពួកគេកំពុងតែជិតស្លាប់ ដោយមិនបានស្គាល់ព្រះគ្រិស្ត។ ឥឡូវខ្ញុំមានមួយលាននាក់នៅទីនេះត្រូវអធិប្បាយ ប៉ុន្តែ មានអ្វីមួយនៅក្នុងចិត្តខ្ញុំកំពុងតែប្រាប់ខ្ញុំ "ចូរដើរឆ្លងទៅកាន់មនុស្សទាំងអស់នោះ។ ចូលទៅកាន់ពួកគេ។ ពួកគេកំពុងតែវិនាស។" ខ្ញុំខ្លួនឯងមិនចង់ចូលទៅទេ ប៉ុន្តែមានអ្វីមួយនៅក្នុងខ្ញុំ។ ឃើញទេ បន្ទាប់មកនោះគឺជាព្រះជាម្ចាស់កំពុងធ្វើចលនា។

ឃើញទេ អ្វីទៅគឺជាគោលបំណង ឃើញទេ អ្វីទៅគឺជាការជំរុញទឹកចិត្ត គឺការចូលទៅកាន់ មិនមែនសម្រាប់ខ្លួនឯងនោះទេ...ពេលនេះប្រសិនបើខ្ញុំ និយាយថា "ល្អ..." ប្រសិនបើគោលបំណងរបស់ខ្ញុំត្រឹមត្រូវ ដើម្បីចូលទៅកាន់ទីនោះ ប៉ុន្តែក្រោយមកខ្ញុំក្រោកឡើងនៅទីនេះ ហើយទីនេះគឺមានភ្នំធំមួយ។ ខ្ញុំនិយាយថា "អ្នកដឹងទេ ប្រសិនបើខ្ញុំ ដើរឆ្លងកាត់ភ្នំមួយនោះ ហើយសង្គ្រោះ មនុស្សទាំងមួយរយនាក់នោះថ្ងៃមួយ ពួកគេនិងមានរូបចម្លាក់នៅទីនោះ បងប្រុសប្រានហាំ(Branham)គឺជាបេសកជនដ៏អស្ចារ្យបំផុត។" ឥឡូវនេះ ការជំរុញចិត្តរបស់ខ្ញុំគឺមិនត្រឹមត្រូវ។ ភ្នំមិនបានរើចេញទេ។ អត់ទេ លោក។

24 ប៉ុន្តែ នៅពេលការជំរុញទឹកចិត្ត និងគោលបំណងរបស់ខ្ញុំត្រឹមត្រូវ ហើយព្រះជាម្ចាស់គង់នៅក្នុងចិត្តរបស់ខ្ញុំ គឺទ្រង់កំពុងតែដឹកនាំខ្ញុំ ហើយខ្ញុំមិនអាចរំលងទៅកាន់ភ្នំនោះ មិនទៅជុំវិញភ្នំ មិននៅក្រោមភ្នំ ខ្ញុំនឹងនិយាយថា "ភ្នំរើ ចេញទៅ។" ប្រហែលជា វា...នៅពេលខ្ញុំនិយាយដូច្នេះ ហើយមិនលើសពីការដែលខ្ញុំនិយាយជាមួយវិញ្ញាណដ៏ត្រឹមត្រូវ បានដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធ នៅក្នុងបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ប្រហែលជាមិនអាចទៅរួចទេ ប៉ុន្តែភ្នំមួយស្លាបព្រាបានធ្លាក់ចុះ ប៉ុន្តែវាកំពុងនៅតាមផ្លូវ។ ថ្ងៃបន្ទាប់នោះ ប្រហែលជាពីផោនធ្លាក់ចុះ។ ថ្ងៃបន្ទាប់មកទៀត កន្លះតោនធ្លាក់ចុះ។ ហើយប្រហែលជាមួយខែ ប្រាំតោនធ្លាក់ចុះ។ តើនោះគឺជាអ្វី? ប្រហែលជាមិនទាន់ឃើញវាទេប៉ុន្តែវាកំពុងតែធ្វើចលនានៅ តាមផ្លូវហើយ។ ខ្ញុំនឹងឈរនៅទីនេះហើយមើលពីការដែលត្រូវបានធ្វើនោះព្រោះ ព្រះបានមានបន្ទូលដូច្នេះ ហើយត្រូវតែសម្រេច។

25 តើអ្នកអាចគិតអំពីម្តាយរបស់អ្នកនៅយប់នេះទេ? ត្រូវហើយ ប្រសិនបើអ្នកគិតពីការនេះ គាត់នឹងបានប្រសើរ។ ពិតណាស់ ប្រសិនបើអ្នកគ្រាន់ តែមានជំនឿពីការនេះ គ្រាន់តែនិយាយពីព្រះបន្ទូល និង នៅជាប់ជាមួយព្រះបន្ទូលនេះ។ ឃើញទេ? គ្រាន់តែជឿលើការនេះ នៅជាប់ជាមួយវា។ វាគឺជាជីវិត អស់កល្ប។

26 ឥឡូវ នៅរសៀលថ្ងៃស្អែក...ខ្ញុំបានប្រាប់ប៊ីលី(Billy)នៅយប់នេះគ្រាន់តែលុបចោលកាតអធិស្ឋានទាំងនេះ ហើយខ្ញុំចង់និយាយ។ ខ្ញុំ សារភាព ក្នុងសេចក្តីពិត ខ្ញុំបានធ្វើតាំងពីខែមករាមកម្លេះ នៅក្រៅប្រទេស និងត្រឡប់មកផ្ទះវិញនៅហ្វូននិច ហើយការទាំងអស់បានបញ្ចប់(នោះជាការសម្រេច)រហូតដល់ខ្ញុំទន់ខ្សោយខ្លាំង ខ្ញុំពិតពិបាកនឹងដឹងថាខ្ញុំនៅទីណាណាស់ នៅពេលនោះ។ វា

គ្រាន់តែជាការពញ្ញាក់អារម្មណ៍ខ្ញុំប៉ុនោះ។

27 ហើយ បន្ទាប់មក ខ្ញុំត្រូវតែចាកចេញ ហើយពួកគេ—អ្នក—អ្នករួមជំនឿ បានអញ្ជើញខ្ញុំ ដើម្បីស្នាក់នៅប៉ុន្មានថ្ងៃទៀត។ ខ្ញុំពិតជារីករាយចំពោះការនោះណាស់។ ខ្ញុំពិតជាគិតថា នេះគឺជាក្រុមអ្នកដឹកនាំដ៏អស្ចារ្យបំផុតនៅទីនេះ។ ជូនពរឲ្យយើងអាចមានពេលវេលាបន្តទៀតក្នុងការប្រកបគ្នា។ ប្រសិនបើជាបំណងរបស់ ព្រះ ខ្ញុំនឹងវិលត្រឡប់មកវិញនៅពេលមួយ។ គ្មានអ្វីទៀតទេ គ្រាន់តែចេញពីក្រុមជំនុំមួយ ទៅកាន់ក្រុមជំនុំមួយទៀត នឹងធ្វើដំណើរ កាត់ជុំវិញទីក្រុង និងសួរសុខទុក្ខអ្នកទាំងអស់គ្នា។ ខ្ញុំសប្បាយរីករាយក្នុងការធ្វើ បែបនោះ អ្វីក៏ដោយដែលខ្ញុំអាចធ្វើបាន ដើម្បីជួយដល់អាណាចក្ររបស់ព្រះជាម្ចាស់ គឺបែបនោះហើយ ប្រសិនបើអ្នកមានបំណងចង់ឲ្យខ្ញុំធ្វើកិច្ចការនេះ។ ហើយអាច ត្រឡប់មកវិញនៅពេលណាមួយ ហើយចូលរួមជាមួយពួកយើង នឹងមានការជួបជុំដ៏សប្បាយរីករាយនៅកន្លែងណាមួយ។

28 ហើយ សូមចង់ចាំថា បងប្អូនអើយ ខ្ញុំនឹងអធិស្ឋានសម្រាប់អ្នក។ នោះគឺជារឿងពិតប្រាកដ។ ហើយខ្ញុំចង់ឲ្យអ្នកទាំងអស់គ្នាអធិស្ឋានសម្រាប់ខ្ញុំ គឺអ្នកទាំងអស់គ្នា។

29 ហើយឥឡូវនេះខ្ញុំ—ខ្ញុំ...នៅព្រឹកស្អែកគឺមានថ្វាយបង្គំនៅគ្រប់ព្រះវិហារផ្សេងៗជុំវិញទីក្រុងនេះ។

30 ឥឡូវនេះ ក្រុមមួយចំនួនមកពី ជេសហ្វឺសាន់វីល (Jeffersonville) គឺនៅទីនេះ។ មិត្តរបស់ខ្ញុំមួយចំនួន ជាម្នាក់ដែលខ្ញុំទុកចិត្តនៅក្នុងក្រុមជំនុំ គឺនៅទីនេះ គឺប្អូនប្រុស ហ្វ្រេដសូថម៉ែន (Fred Sothman)។ ខ្ញុំមិនធ្លាប់បានជួបគាត់នៅក្នុងការប្រជុំឡើយ។ ហើយនឹងប្អូនប្រុស...អូ មានមិត្តរបស់ខ្ញុំជា ច្រើនទៀតនៅទីនេះមកពីជេសហ្វឺសាន់វីល (Jeffersonville) ដំបូងខ្ញុំ-...អ្នកជំនួយការរបស់ខ្ញុំនៅទីនេះ ហើយ—ហើយគ្រប់គ្នាគឺនៅទីនេះ នៅទីកន្លែងណាមួយ នៅក្នុងការប្រជុំនេះ។ ខ្ញុំមិនទាន់បានជួបពួកគេនៅឡើយទេ។

31 ហើយ បងប្អូនអើយមាន ក្រុមជំនុំល្អៗមួយចំនួននៅទីក្រុងនេះ។ ហើយអ្នកទាំងអស់គ្នាអាចរកព្រះវិហារណាមួយ ដើម្បីថ្វាយបង្គំនៅថ្ងៃស្អែក។ ពួកគេនឹងបម្រើអ្នកបានល្អ ខ្ញុំដឹងប្រាកដណាស់។ ពួកគេជាបងប្អូន ដែលជាអ្នកជឿទៅ លើព័ន្ធកិច្ចបែបនេះ។ នោះហើយគឺជាហេតុផលដែលពួកគេនៅទីនេះ នៅលើវេទិកា

រនិងនៅខាងក្រោមនេះ ពីព្រោះពួកគេជឿការនេះ។ ហើយខ្ញុំក៏សាទរចំពោះពួកគេទាំងនោះដែរ។

32 ព្រះជាម្ចាស់ សូមប្រទានពរដល់ក្រុមអ្នកផ្សាយដំណឹងល្អ (Full Gospel Businessmen) ទីនេះ ជាអ្នក—ជាអ្នកដែលបានឧបត្ថម្ភនៅក្នុង កិច្ចប្រជុំនេះ។ គឺមាន...ខ្ញុំជឿថាគឺជាការត្រឹមត្រូវ ដែលបានឧបត្ថម្ភនៅក្នុងកិច្ច ប្រជុំនេះ។ ខ្ញុំ—ខ្ញុំទទួលបានការឧបត្ថម្ភពី ពួកគេយ៉ាងច្រើន ដោយព្រោះទីនោះ...យើងមិនអាច នឹងបានបែបនេះទេ ប៉ុន្តែជាច្រើនដង បងប្អូនរួមជំនឿមាន ភាពខុសប្លែកពីគ្នាបន្តិចដូចជាមនុស្ស*ខ្លះជឿនេះ*តិច ហើយជឿការ*មួយទៀត*បន្តិចគឺជាប្រភេទនៃការប្រិះស្រាំបន្តិចបន្តួច ការឈឺចាប់នៅលើរាងកាយ ចាស់ចេញឆ្ងាយទៅ។ វាគួរតែត្រូវបានព្យាបាលឡើង នៅពេលនេះប៉ុន្តែវា—វា...ហើយ ប្រសិនបើអ្នក—ប្រសិនបើខ្ញុំទទួលបានអ្នកបម្រើរដំណឹងល្អដ៏ពេញលេញ បន្ទាប់មកការជួយរបៀបនោះចងភ្ជាប់គ្នា ហើយយើងបានរួមជាមួយគ្នា ហើយយើងមានការប្រកបគ្នាដ៏ពិតរួមគ្នា គឺជាពេលដ៏ល្អមួយ។ ហើយយើងសារទរចំពោះការនោះ។ សូមព្រះជាម្ចាស់ប្រទានពរនៅវគ្គនេះ។ ខ្ញុំជឿថាព្រះជាម្ចាស់នឹងលើកការនេះឡើង ដោយបំណងព្រះហឫទ័យ។

33 ឥឡូវនេះ...ហើយបន្ទាប់មក ខ្ញុំមានអភ័យឯកសិទ្ធិដោយបានឃើញ ប្អូនប្រុស អូរ៉ុល រ៉ូប៊ឺត (Oral Roberts)នៅថ្ងៃមួយទៀត។ ហើយកន្លែងដ៏ ធំបំផុតរបស់ខ្ញុំដូចជារបស់ដ៏ស្រស់ស្អាតបំផុត។ វាគឺ—គឺជាការចងចាំពី បុណ្យថ្ងៃទីហាសិប។

34 ក្រោយមក ខ្ញុំបានទៅជួបប្អូនប្រុស តូមី អូស្បូន (Tommy Osborn) នៅកន្លែងដ៏ស្រស់ស្អាតមួយទៀត មនុស្សដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ ជាអ្នកដែល...ប្អូនប្រុសតូមី(Tommy)ហើយនឹងខ្ញុំជិតស្និទ្ធជាមួយគ្នា នឹងប្អូនប្រុសអូរ៉ុល (Oral) ដែរ គ្រាន់តែជាបងប្អូនប្រុសដ៏ស្និទ្ធស្នាលហើយយើងក៏ស្រឡាញ់អ្នក ដទៃដែរ នឹងព្យាយាមអស់ពីសមត្ថភាពរបស់យើងដើម្បីធ្វើគ្រប់កិច្ចការទាំងអស់ដែលយើងអាចធ្វើសម្រាប់ការល្អដល់មនុស្សនៅក្នុងអាណាចក្ររបស់ព្រះជាម្ចាស់។

35 ដូច្នេះហើយ ខ្ញុំពិតជាត្រេកអរចំពោះពួកគេទាំងនោះ ដែលបានមកក្នុងទីក្រុងនេះ នៅក្នុងចំណោមមនុស្សល្អទាំងនេះដែលអ្នកបានទៅជួប។ អ្នកជាចៀមដែលមានអ្នកគង្វាលដ៏អស្ចារ្យជាច្រើន។ ខ្ញុំគ្រាន់តែ ខ្ញុំនឹងនិយាយវាបែបនោះ។ សូមឲ្យព្រះជាម្ចាស់គង់នៅជាមួយអ្នករាល់គ្នា នៅក្នុងការអធិស្ឋានរបស់ខ្ញុំ។ ហើយឥឡូវ

នៅរសៀលថ្ងៃស្អែក ខ្ញុំ...តើការថ្វាយបង្គំចាប់ផ្តើមនៅម៉ោង ប៉ុន្មាន បងប្អូន? ម៉ោងពីរកន្លះ។ យើងអាចនិយាយបានថាម៉ោងមួយ—ម៉ោងមួយ ឬក៏មួយកន្លះអ្នកគួរតែនៅកន្លែងនេះ ដូចនេះពួកគេមិនអាចរំខានដល់កម្មវិធីផ្សេងទៀតទេ។

36 ឥឡូវប្រសិនបើក្មេងប្រុសទាំងនេះមិនទាន់បានប្រាប់អ្នក នៅយប់នេះ ពួកគេមានសៀវភៅ រូបភាព នឹងរបស់ជាច្រើនទៀត ហើយនឹងការសែត នឹងឯកសារហើយ...នៃការប្រជុំហើយពួកគេលក់របស់ទាំងនោះ។ ប៉ុន្តែយើងនឹងមិនអនុញ្ញាតឲ្យពួកគេលក់របស់ទាំងនោះនៅថ្ងៃឈប់សំរាកថ្ងៃស្អែកឡើយ។ គ្មានសៀវភៅនិងអ្វីៗផ្សេងទៀតត្រូវលក់ឡើយនៅថ្ងៃស្អែក។ ដូច្នេះយើង មិន—យើង មិនដែលអនុញ្ញាតឲ្យមានបែបនោះទេ។ បើទោះបីជាមានមនុស្សជា ច្រើននិយាយថា "អ្នកពិតជាខុសខ្លាំងណាស់..."

37 ហើយ ឪពុកវ័យចំណាស់ប៊ូសវ៉ឺស (Bosworth) ធ្លាប់ប្រាប់ខ្ញុំថា "អូ ប្អូនប្រុសប្រានហាំ អ្នកគឺមានកំហុសនៅចំនុចនោះហើយ" ប៉ុន្តែនោះគឺជាវិធីខ្ញុំ (យើញ?) ហើយខ្ញុំ—ខ្ញុំមានអារម្មណ៍ថា។ ប្រសិនបើ អ្នកត្រូវការមួយ ពួកគេនឹងឲ្យអ្នកមួយ ប៉ុន្តែប្រសិនបើអ្នក...ប៉ុន្តែយើងមិនអាចលក់នៅ—នៅថ្ងៃឈប់សំរាក។ ទេ។ គឺបែបនោះហើយ។ ប្រសិនបើ ខ្ញុំជឿការនោះ ខ្ញុំត្រូវតែរស់នៅ គ្រាន់តែ...ខ្ញុំគ្រាន់តែរស់នៅដោយខ្លួនឯងផ្ទាល់។ អ្នកឃើញទេ? ហើយ ខ្ញុំ—ខ្ញុំត្រូវតែរស់នៅដោយ ភាពជឿជាក់ នឹង...ឬក៏អ្នកអាចបញ្ជូលត្រឡប់ទៅផ្ទះវិញនឹងទៅដល់ផ្ទះ ទៅដល់កន្លែងហើយបានទទួលពីការនេះ។

38 ឥឡូវនៅយប់នេះ អូ ចូរគ្រាន់តែបំភ្លេចការនោះ អូ មានកិច្ចការជា ច្រើនដែលត្រូវបញ្ចប់ ឬក៏មានរឿងអ្វីផ្សេងទៀត ឬជាការងារលំបាកប្រចាំថ្ងៃ។ សូមដាក់ការទាំងអស់ ឲ្យនៅមួយឡែក ហើយមើលទៅកាន់ព្រះបន្ទូលរយៈពេលពីរបីនាទីហើយនឹងឃើញពីអ្វី ដែលព្រះនឹងនិយាយមកកាន់ យើងតាមរយៈព្រះបន្ទូលរបស់ទ្រង់។ ហើយសូមឲ្យខ្ញុំអធិស្ឋាន សូមឲ្យព្រះប្រទានពរដ៏អស្ចារ្យសម្រាប់ យើងនៅយប់នេះ។

39 ហ្គេននី (Gene) តើអ្នកអាចចាប់នាងឲ្យខ្ញុំបានទេ? តើអ្នកអាចចាប់ក្មេងស្រីតូចម្នាក់នោះឲ្យខ្ញុំបានទេ? តើនាងពិតជាស្អាតដូចជាអ្វីមួយទេ? តើអ្នកចង់ទៅផ្ទះ ជាមួយខ្ញុំ នឹងលេងជាមួយកូនតូចរបស់ខ្ញុំសារ៉ា *ប្រហែល*កម្ពស់នេះដែរទេ? អូ អ្នក នឹង? ខ្ញុំ—ខ្ញុំក៏ចូលចិត្តអ្នកដែរ។ នាងក៏មានរូបរាងដូចអ្នកដែរ ហើយ

នាង ជាកូនតូចរបស់ខ្ញុំ។ អឺម។ អឺម។ ហើយ ខ្ញុំភ្នាល់ថាអ្នក—អ្នកក៏ស្រឡាញ់ប៉ា របស់អ្នកដែរ មែនឬ? អ្នកម៉ាក់? អូ ជាការពិតអ្នកស្រឡាញ់ពួកគាត់។ ក្មេងស្រី ដ៏ ស្រស់ស្អាតបំផុត ខ្ញុំកំពុងតែអង្គុយនៅទីនេះ កំពុងតែមើលនាង។ កែវភ្នែកដ៏ តូចមើលទៅដូចជារន្ធពីរឆេះនៅក្នុងផ្ទាំងក្រណាត់ ហើយ—ហើយមានសក់ ព៌ណ ត្នោត។

40 ខ្ញុំគ្រាន់តែស្រឡាញ់ក្មេងតូចៗ។ ខ្ញុំមានកូនស្រីពីរនាក់នៅផ្ទះ។ ម្នាក់ឈ្មោះ រេ បេកា (Rebekah) ហើយ ម្នាក់ទៀតឈ្មោះ សារ៉ា (sarah)។

41 នៅទីនេះ កាលពីមួយរយៈពេលមុន ខ្ញុំបានទៅឆ្ងាយ។ កូនស្រីតូច ទាំងពីរ។ ដូចដែលអ្នកដឹងហើយ ខ្ញុំស្រឡាញ់ពួកគេ។ ហើយកាលណាពួកគេចូលមក ខ្ញុំ ត្រូវតែឲ្យពួកគេជិះលើខ្នងខ្ញុំ នឹង...មានតែប៊ែកគី(Becky)ទេដែលធំ នាងមាន មាឌធំដូចជាខ្ញុំ។ នាងធ្វើឲ្យខ្ញុំឈឺខ្នងឥឡូវ នាង...តែទោះជាយ៉ាង ណា នាង នៅតែជាកូនស្រីតូចរបស់ខ្ញុំ។ ហើយពេលនេះ ប្រហែលជាឆ្នាំក្រោយ យើងចង់ឲ្យ នាងចូលរៀនសាលាព្រះគម្ពីរនៅកន្លែងណាមួយ ហើយឲ្យឆ្ងាយពីសាលារដ្ឋ។

42 ហើយបន្ទាប់—ពួកគេកំពុងតែរង់ចាំផ្លូវរបស់លោកប៉ា អ្នកដឹងទេ គឺត្រឡប់ មកផ្ទះវិញ។ ខ្ញុំបានចេញមកក្រៅដើម្បីប្រជុំ។ ហើយនៅយប់ថ្ងៃស្អែក ពួកគេនឹង រង់ចាំផ្លូវខ្ញុំហូតដល់យប់ជ្រៅ រង់ចាំខ្ញុំមកដល់ផ្ទះ។ ដូច្នេះហើយ ខ្ញុំត្រូវតែមកដល់ នៅពេលព្រឹកព្រលឹម ប្រហែលជាម៉ោងបី ឬក៏ម៉ោងបួនគត់។ ហើយ ប្រពន្ធរបស់ខ្ញុំ មកបើកទ្វារឲ្យខ្ញុំចូលក្នុងផ្ទះ ហើយខ្ញុំអស់កំលាំងនិងនឿយហត់យ៉ាងខ្លាំង ខ្ញុំ...នៅ ទីនេះនៅលើវេទិការ ខ្ញុំ...នៅពេល...ដែលបានចាក់ប្រេងតាំង ខ្ញុំមានអារម្មណ៍ល្អ ប៉ុន្តែនៅពេលដែលមួយនោះ បានផុតចេញពីអ្នកទៅ នោះគឺជាពេលដែលអ្នកមាន បញ្ហា។ តើមានប៉ុន្មាននាក់ បានដឹងពីការនោះ? ហេតុអ្វី ពិតណាស់គឺបែប នោះ ហើយ។

43 ចូរក្រឡេកមើល។ លោកអេលីយ៉ា បានឡើងទៅលើកំពូលភ្នំ ហើយបានហៅ ភ្លើងពីស្ថានសួគ៌ ហៅភ្លៀងមកពីស្ថានសួគ៌ បន្ទាប់ពីព្រះវិញ្ញាណចេញពីគាត់ គាត់ បានវង្វេង នៅវាលរហោស្ថានអស់រយៈពេលសែបសិបថ្ងៃ ហើយព្រះជាម្ចាស់បាន រកគាត់ឃើញ នាំយកគាត់ទៅក្នុងរូងភ្នំនៅកន្លែងមួយ។

44 លោកយ៉ូណាសគាត់បានធ្លាក់ចុះហើយបានរស់នៅក្នុងពោះរបស់ត្រី បាឡែន អស់រយៈពេលបីយប់ បីថ្ងៃ ហើយបានចេញពីមាត់ត្រី នឹងបាន ចេញផ្សាយ

ដំណឹងល្អ។ ទីក្រុងទាំងមូលបានដឹងខ្លួន និងត្រឡប់ទៅកាន់ ព្រះជាម្ចាស់។ ហើយនៅពេលការចាក់ប្រេងតាំងបានចេញពីគាត់ គាត់បានឡើង ទៅលើកំពូលភ្នំ នឹងអធិស្ឋានឲ្យព្រះយកជីវិតរបស់គាត់។ ឃើញទេ?

45 ខ្ញុំ បានឈរនៅក្បែរផ្នូររបស់វីលៀមខូភើ(William Cowper)មិនជាយូរ ប៉ុន្មានទេ ដែលបានសរសេរពីបទចម្រៀងថ្វាយព្រះ ដែលយើងធ្លាប់បានច្រៀង សម្រប់ពេលថ្វាយបង្គំ:

មានឈាមវិសេស
ហូរមកលោះបាបចេញពីរបួសព្រះអង្គ
ឯមនុស្សមានបាបបើចូលទៅក្រាបនោះទ្រង់...

46 តើអ្នកធ្លាប់បានឮពីអ្វីដែលគាត់...បានកើតឡើងទៅចំពោះគាត់ទេ? បន្ទាប់ពីការជំរុញទឹកចិត្តបានចាកចេញពីគាត់ទៅគាត់បានព្យាយាមស្វែងរក ស្ទឹង ដើម្បីធ្វើអត្តឃាត។

47 ខ្ញុំរស់នៅឆ្ងាយពីផ្ទះចាស់កេនតាក់គី (Kentucky)។ ហើយស្ទេហ្វិនហ្វស្ទើរ (Stephen Foster) បានផ្តល់ឲ្យនូវបទចម្រៀងប្រពៃណីរបស់អាមេរិកដ៏ពិរោះ បំផុត។ ហើយនៅពេលគាត់បានសរសេរ គាត់បានទទួលការបណ្តាលចិត្ត ការជំរុញទឹកចិត្តនោះ គឺជាការតែងបទចម្រៀង បន្ទាប់មកពេលគាត់ផុតពីការជំរុញទឹកចិត្ត គាត់ក៏បានស្រវឹង។ ទីបំផុត គាត់បានហៅអ្នកបម្រើម្នាក់ ហើយបានយកកាំបិតកោរពុកមាត់មួយ ហើយបានធ្វើអត្តឃាត។

48 មនុស្ស មិនបានដឹងពីអ្វីដែលពួកគេទាំងអស់នោះបានឆ្លងកាត់ ការរស់នៅជាមួយនឹងអាណាចក្រនៃព្រះវិញ្ញាណនោះទេ។ ពេលនេះ *ទីនេះ* អ្នកមានអារម្មណ៍ថាអ្នកអាចរើភ្នំចេញបាន ប៉ុន្តែសូមឲ្យការប្រេងតាំងបានហូរនៅលើអ្នក ហើយចាប់ផ្តើមឆ្លងកាត់តាមទ្វារនោះ...ប្រសិនបើមិនមាននរណាម្នាក់នៅទីនោះចាប់អ្នកទេ...ឃើញទេ? ហើយបន្ទាប់មក ប្រហែលជាពីរបីម៉ោងអ្នកពិបាកនឹងដឹងថាអ្នកនៅកន្លែងណា។ បន្ទាប់មក ពីមួយយប់ទៅមួយយប់ នោះនឹងជាការល្អ បំផុតសម្រាប់អ្នក។

49 ហើយរឿងតិចតួច...ចង់ប្រាប់អំពីក្មេងតូចសារា(Sarah)នឹង រេបេកា (Rebekah)។ ដូច្នេះហើយ នៅព្រឹកបន្ទាប់ ខ្ញុំមិនអាចគេងបានទេ ហើយខ្ញុំ

នឹង ក្រោកឡើងកំពុងតែអង្គុយនៅលើកៅអីមួយហើយបន្តិចក្រោយមក បេគី (Becky) ដែលជាបងគេបង្អស់ នាងបាន—មានជើងវែង ជាងសារា ដូច្នេះហើយ បេគី រត់ចូលមក...ក្រោកឡើង លោតចុះពីលើគ្រែ ដោយមិនបានធ្វើឲ្យប្អូនស្រីតូចរបស់នាងភ្ញាក់ឡើយ នៅទីនេះហើយ ដែលនាងបានរត់ជុំវិញផ្ទះ រត់យ៉ាងខ្លាំង តាមតែនាងធ្វើទៅបាន។ នាងបាននិយាយថា "លោកប៉ា លោកប៉ា..." ខ្ញុំបានដាក់ ជើងទាំងពីររបស់ខ្ញុំ ហើយនាងបានរត់កាត់ជើងនោះ ដោយស្មើគ្នាល្អណាស់។ ប្រភេទដូចជា—ព្រះវិហារដ៏ទំនើបអ្នកដឹងទេវាជាការល្បែងកំសាន្តជាយូរមកហើយ អ្នកដឹងទេ អស់រយៈពេលប៉ុន្មានរយឆ្នាំកន្លងផុត ទៅហើយ។ នាងអាចធ្វើឲ្យខ្លួនរបស់នាងស្ថិតនៅស្មើគ្នាបានល្អ ហើយនាងបាន ដាក់ដៃរបស់នាងអោបខ្ញុំជុំវិញ ហើយនិយាយថា "អូ លោកប៉ារបស់ខ្ញុំ លោកប៉ា របស់ខ្ញុំ..."

50 ហើយសារាមានការភ្ញាក់ផ្អើល បានភ្ញាក់ឡើង។ ហើយខ្ញុំមិនដឹងថាតើកូនរបស់អ្នកធ្វើបែបនេះ ឬក៏អត់ទេ កូនរបស់ខ្ញុំបានធ្វើបែបនេះ: កូនតូចបំផុតរបស់ខ្ញុំបានយកសម្លៀកបំពាក់។ ដូច្នេះហើយ សារាបានពាក់សម្លៀកបំពាក់គេងរបស់បេគី ជើងដូចជាវែងខ្លាំងណាស់ អ្នកដឹងទេ។ ហើយនៅទីនេះ នាងបានមក កូនតូចគួរឲ្យស្រឡាញ់បានដួល ជំពប់ជើងដួល។ ហើយនាងបានមកដល់ទីនេះ យឺតបន្តិចហើយ។ ដូច្នេះហើយ បេគីបែត្រឡប់ក្រោយ បាននិយាយថា "សារា ប្អូនស្រីរបស់ខ្ញុំ ខ្ញុំចង់ប្រាប់រឿងមួយដល់ប្អូន។" នាងបាននិយាយថា "ខ្ញុំបានមកដល់ទីនេះមុន។ ហើយខ្ញុំមានសិទ្ធិផ្តាច់មុខ។ ដូច្នេះខ្ញុំបានលោកប៉ាទាំងអស់ គ្មានអ្វីសល់សម្រាប់ឯងទេ។"

51 នោះហើយ ជាវិធីដែលមនុស្សមួយចំនួនព្យាយាម ដើម្បីគិតអំពីសាសនាពិតមែនទេ? អា។ ត្រូវហើយ។

52 ហើយ សារាដ៏គួរឲ្យអាណិត នាងបានដាក់បបូរមាត់ដ៏តូចរបស់នាងចុះ ហើយបានដាក់ភ្នែកខ្មៅទាំងពីរ សម្លឹងមកកាន់ខ្ញុំ ហើយនាងបានចាប់ផ្តើមយំ។ ហើយ បេគីបានដាក់ថ្ពាល់ទល់ថ្ពាល់របស់ខ្ញុំ អោបខ្ញុំ។ ខ្ញុំស្រឡាញ់នាង។ ហើយ សារាបានចាប់ផ្តើមដើរចេញទៅ ដោយព្រោះបេគី បានយកលោកប៉ាទាំងអស់ហើយ។ ខ្ញុំបានរំកិលជង្គង់ខ្ញុំ*បែបនោះ* ហើយប្រាប់ទៅនាង*បែបដូចនោះ។* អូ នាងបានងើបមុខឡើងយ៉ាងប្រញាប់ ហើយបានរត់មក បានលោតមកលើជង្គង់របស់ខ្ញុំ ដូច្នេះ...នាងមិនបានទៅណាឆ្ងាយទេ ហើយជើងរបស់នាងមិនទាំងដល់ ឥដ្ឋ

ផង។ នាងដូចជាខ្សោយបន្តិច (ប្រហែលជា ដូចខ្ញុំហើយរាងខ្សោយបន្តិច អ្នកដឹងទេ) ហើយនាងមិនបាន...មិនបានដល់ឥដ្ឋឡើយ។ នាងមិនមានមាឌធំប៉ុន្មានទេដឹងទេ ដូច្នេះហើយនាងមិនអាចដើរផ្ទាល់ទៅនឹងឥដ្ឋរឹងបានទេ។ នាងក៏មិនអាចដើរជុំវិញឆ្ងាយបានដែរ។

53 ដូច្នេះហើយនាងគឺទន់ខ្សោយហើយខ្ញុំបានដាក់ដៃទាំងពីររបស់ ខ្ញុំជុំវិញនាងដូច *នេះ* ហើយបានអោបនាងឲ្យជាប់ជិតខ្ញុំ ហើយនាងបានបញ្ចេញ ពន្លឺភ្នែកពណ៌ខ្មៅតូចទាំងពីរនោះ ហើយក្រឡេកទៅមើលរេបេកា។ នាងបាននិយាយថា "រេបេកា បងស្រី" នាង—នាងបាននិយាយ "វាប្រហែលជា ពិតប្រាកដដែលបងយកបានប៉ាទាំងអស់ ប៉ុន្តែខ្ញុំចង់ឲ្យបងដឹងរឿងមួយ លោកប៉ាបានខ្ញុំទាំងអស់។" ដូច្នេះ...

54 នោះគឺ...គ្រាន់តែបែបនោះគាត់បានខ្ញុំទាំងអស់។ ខ្ញុំប្រហែលជាមិនចាំបាច់ការអប់រំដើម្បីដាក់លើការធំនោះឡើយប៉ុន្តែគ្រាន់តែខ្ញុំដឹងថាគាត់មានភាពកំសោយទាំងអស់របស់ខ្ញុំ ហើយគ្រាន់តែឲ្យគាត់ដាក់ដៃជុំវិញខ្ញុំ គឺធ្វើឲ្យខ្ញុំមានអារម្មណ៍ល្អណាស់។

55 ល្អសូមយើងថ្វាយការអធិស្ឋានម្តងទៀតមុនពេលយើងបើកព្រះបន្ទូលទ្រង់។

56 ឥឡូវនេះ ឱព្រះវរបិតាដែលគង់នៅស្ថានសួគ៌អើយ យើងបានដឹងថា យើងក៏ដូចជាកូនក្មេងដែរ។ ហើយ—ហើយទ្រង់សព្វព្រះហឫទ័យគង់នៅជាមួយយើងហើយថ្វាយបង្គំជាមួយយើង។ ហើយពេលយើងថ្វាយបង្គំ ទ្រង់ គឺទ្រង់ស្រឡាញ់យើង ហើយទ្រង់អោបយើងនៅក្នុងព្រះហស្តទ្រង់ ហើយសូម បញ្ជូនព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់ចុះមក ហើយសូមធ្វើឲ្យយើងដឹងថា ទ្រង់ជា ព្រះដ៏រស់ ហើយទ្រង់ក៏ជាព្រះវរបិតារបស់យើងដែរ យើងសូមថ្វាយការអរព្រះគុណ យ៉ាងខ្លាំងទៅកាន់ទ្រង់។ ឥឡូវនេះសូមឲ្យព្រះវិញ្ញាណបរិសុទ្ធយាងមកកាន់យើង នៅយប់នេះ។ សូមសេចក្តីស្រឡាញ់មានក្នុងដួងចិត្តម្នាក់ៗ ព្រះអម្ចាស់អើយ។ សូមប្រទានឲ្យយើងនូវព្រះពរស្រស់ស្អាត។ សូមចាក់បង្ហូរសេចក្តីមេត្តាដល់យើង។ សូមកុំមើលពីអំពើបាបរបស់យើងឡើយ។ អំពើបាបរបស់យើងច្រើនណាស់។ ព្រះជាម្ចាស់សូមអត់ទោសអំពើបាបទាំងនោះ។ សូមលុបបំបាត់បាបនោះទៅ ព្រះបិតាអើយ ហើយសូមយកយើងដាក់ក្នុងព្រះហស្តទ្រង់ ហើយ—ហើយព្យាបាល ជំងឺរបស់យើង និង—និងសម្អាតព្រលឹងរបស់យើង នឹងសូមឲ្យវិញ្ញាណរបស់យើង មាន

សិរីភាព ឱព្រះជាម្ចាស់ ដែលយើងអាចថ្វាយបង្គំ ហើយសរសើរព្រះអង្គ ដូចជាកូនក្មេងកំពុងតែរត់លេងនៅជុំវិញផ្ទះដោយគ្រាន់តែដឹងថា ឪពុកកំពុងតែមើលយើង។ សូម ទទួលយកការអធិស្ឋាននេះព្រះអម្ចាស់អើយ។

57 ឥឡូវនេះ គ្មាននរណាម្នាក់អាច—អាចបកស្រាយពីព្រះបន្ទូលបានឡើយ។ យើងដឹងថា លោកយ៉ូហាន បានឃើញសៀវភៅនៅព្រះហស្ថរបស់ទ្រង់ ដែល បានដាក់នៅលើបល្ល័ង្គ ហើយគ្មាននរណាម្នាក់នៅស្ថានសួគ៌ ឬក៏នៅលើផែនដី ឬក៏នៅក្បែផែនដីដែលមានតម្លៃ ដើម្បីយកកណ្ដូសៀវភៅនោះ ដើម្បីបើកឡើយ ឬក៏ធ្វើឲ្យបាត់ត្រាឡើយ។ ហើយមានចៀមមួយលេចឡើង ដែលបានសម្លាប់ ចាប់តាំងពីកំណើតពិភពលោកមក។ ហើយទ្រង់គឺមានតម្លៃ។ ហើយទ្រង់បានយកកណ្ដូសៀវភៅនោះ នឹងយកត្រានោះចេញ នឹងបានបើកកណ្ដូសៀវភៅនោះឡើង។ អូ កូនចៀមយាងមកនៅយប់នេះ។ ឱព្រះវរបិតា សូមបើកកណ្ដូនោះដល់យើង ដូចដែលយើង បានរង់ចាំទ្រង់ យើងសូមអធិស្ឋានសុំនៅក្នុងព្រះនាមព្រះយេស៊ូជាកូនចៀមនៃព្រះ។ អាម៉ែន។

58 ខ្ញុំ ត្រូវបានជ្រើសរើសយកនៅយប់នេះ ខគម្ពីរខ្លីមួយនៅទីនេះអស់រយៈពេលបីសប្ដាហ៍មកហើយ។ ប៉ុន្ដែជាដំបូងខ្ញុំចង់អានខគម្ពីរមួយ ឬក៏ពីរពីកណ្ដូបរិសុទ្ធ យ៉ូហាន ជំពូកទី 11 ចាប់ផ្ដើមជាមួយនឹងខ23។

*ព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា៖ ប្អូននាងនឹងរស់ឡើងវិញ។*

*នាងទូលទៅព្រះអង្គវិញថានាងខ្ញុំដឹងហើយ...នៅថ្ងៃចុងក្រោយបំផុត កាលណាមនុស្សស្លាប់នឹងរស់ឡើងវិញ ប្អូននាងខ្ញុំក៏នឹងរស់ ឡើងវិញដែរ។*

*ព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា៖ ខ្ញុំហ្នឹងហើយដែលប្រោសមនុស្សអោយរស់ឡើងវិញ...ខ្ញុំនឹងផ្ដល់អោយគេមានជីវិត។ អ្នកណាជឿលើខ្ញុំ ទោះបីស្លាប់ទៅហើយក៏ដោយ ក៏នឹងបានរស់ជាមិនខាន។*

*រីឯអស់អ្នកដែលកំពុងតែមានជីវិតនៅរស់ ហើយជឿលើខ្ញុំ មិនស្លាប់សោះឡើយ តើនាងជឿសេចក្ដីនេះឬទេ?។*

*នាងម៉ាថាទូលព្រះអង្គថា៖ បពិត្រព្រះអម្ចាស់! ខ្ញុំម្ចាស់ជឿថា ព្រះអង្គពិតជាព្រះគ្រិស្ដ ជាព្រះបុត្រារបស់ព្រះជាម្ចាស់ ហើយពិតជាព្រះអង្គ*

*ដែលត្រូវយាងមកក្នុងពិភពលោកនេះមែន!។*

59 ហើយសម្រាប់មេរៀននេះខ្ញុំ ចង់ប្រើព្រះបន្ទូលទាំងបីនេះ *តើអ្នកជឿការនេះឬទេ?*

60 ខ្ញុំបានអានរឿងមួយជាយូរមកហើយ។ ខ្ញុំគិតថាវាជារឿងប្រឌិត។ ហើយខ្ញុំគិតថាគ្រប់អ្នកដឹកនាំទាំងអស់បានអានរឿងសៀវភៅរបស់លោកដុកទ័រ អ៊ីនហ្គ្រាហាំ (Dr. Ingraham) ជាសៀវភៅនៃ—*អ្នកអង្គម្ចាស់នៃព្រះដំណាក់របស់ស្ដេចដាវីដ។* វាជាសៀវភៅដ៏ល្អ។ វាគឺជា—ខ្ញុំគិតថាវាពិតប្រាកដជាបានបោះពុម្ពហើយ។ ខ្ញុំចង់ ឲ្យសៀវភៅនេះបោះពុម្ពដូច្នេះហើយ ខ្ញុំអាចចែកចាយឲ្យទៅក្នុងចំណោមមនុស្ស។

61 ហើយ នៅទីនេះ ខ្ញុំបានកំពុងតែអានរឿងខ្លីមួយទាក់ទងនឹងលោកឡាសារ ហើយ នឹងព្រះយេស៊ូ នាងម៉ារី ហើយនឹងនាងម៉ាថា ដែលជាបងប្អូនស្រីរបស់លោកឡាសារ។ ហើយខ្ញុំបានកំពុងតែអាននៅកន្លែងដែល ព្រះយេស៊ូបានគង់នៅខ្ញុំជឿ ជាមួយនាងម៉ាថា នឹងម៉ារី។ ពួកគេទាំងពីរជាក្មេងស្រីជនជាតិហេព្រើដ៏គួរឲ្យស្រឡាញ់។ ហើយឡាសារកំពុងតែរៀន នឹងហ្វឹកហាត់ដើម្បីក្លាយជាអ្នកនិពន្ធនៅឯ ព្រះវិហារ សរសេរច្បាប់សម្រាប់ពួកសង្ឃទាំងអស់នោះ។

62 ហើយ ព្រះយេស៊ូមានការប្រកបដ៏ល្អ ជាពិសេសជាមួយលោកឡាសារ។ នៅពេលយើងអានកណ្ឌសៀវភៅ ដែលជាកន្លែងព្រះយេស៊ូបានយាងទៅផ្ទះរបស់ពួកគេ ហើយនាងម៉ាថា គឺបានពន្យាពេលបន្តិចបន្តួចអំពីការស្ដាប់ពីព្រះបន្ទូលរបស់ទ្រង់ ប៉ុន្តែនាងត្រូវតែរៀបចំម្ហូបពេលល្ងាច នឹងរៀបចំ តុ ឲ្យរួចរាល់ប៉ុន្តែនាងម៉ារីបានអង្គុយនៅទៀបព្រះបាទរបស់ទ្រង់។ ហើយព្រះយេស៊ូ បានមានបន្ទូលថា ម៉ារីបានជ្រើសរើសការដ៏ល្អហើយ។

63 ហើយបន្ទាប់មក យើងត្រូវបានប្រាប់ឲ្យដឹងថាលោកឡាសារ គឺជាម្នាក់ដែលបាននាំព្រះយេស៊ូ ទៅកាន់លោកយ៉ូហាន នៅក្នុងសាច់រឿងនៃសៀវភៅរបស់លោកដុកទ័រ អ៊ីនហ្គ្រាហាំ ហើយ...នៅក្នុង *អង្គម្ចាស់នៃព្រះដំណាក់របស់ស្ដេចដាវីឌ។* ទោះជាយ៉ាងណាក៏ដោយ ប្រហែលជាមិនពិតប្រាកដទេ ខ្ញុំមិនបានដឹងច្បាស់ទេ ប៉ុន្តែខ្ញុំគ្រាន់តែដឹងពីប្រវិត្តិរបស់វាតិចតួច ប៉ុន្តែ ទ្រង់មានបំណងហឫទ័យស្នាក់នៅជាមួយពួកគេ។

64 ឥឡូវនេះ យើងបានកំពុងតែរៀនអំពីការយាងមកសប្ដាហ៍មុននេះ ដែលព្រះយេស៊ូបានមានបន្ទូលនៅក្នុងកណ្ឌបរិសុទ្ធយ៉ូហានជំពូកទី5:ខ19 "ខ្ញុំ... ព្រះបុត្រាពុំអាចធ្វើអ្វីដោយព្រះអង្គផ្ទាល់បានឡើយ គឺព្រះបុត្រាធ្វើតែកិច្ចការណា ដែលទ្រង់បានឃើញព្រះបិតាធ្វើ ប៉ុណ្ណោះ។ កិច្ចការអ្វីដែលព្រះបិតាធ្វើ ព្រះបុត្រាក៏ធ្វើកិច្ចការនោះដែរ។" ឃើញទេ? "តើកិច្ចការអ្វីដែលទ្រង់ទតឃើញពីព្រះវរបិតាកំពុងតែធ្វើ។"

65 ដូច្នេះហើយ ដើម្បីធ្វើឲ្យរឿងនេះក្លាយជារឿងពិតប្រាកដ ព្រះវរបិតា ជាព្រះជា ម្ចាស់បានមានបន្ទូលទៅកាន់ព្រះរាជបុត្រារបស់ទ្រង់ គឺព្រះយេស៊ូ ហើយមាន បន្ទូលថា "មិត្តរបស់អ្នកឡាសារ នឹងត្រូវស្លាប់ ប៉ុន្តែវាសម្រាប់ជាការល្អវិញ ដូច្នេះ អ្នកត្រូវចាកចេញពីផ្ទះ។ ទៅឲ្យឆ្ងាយ ដោយព្រោះការនេះនឹងសុំអ្នកឲ្យអធិស្ឋានសម្រាប់គាត់ឬក៏ធ្វើឲ្យគាត់ជាឡើងវិញ ហើយ—ហើយខ្ញុំមិនចង់ឲ្យអ្នកធ្វើការបែបនោះឡើយ។" ប្រសិនបើអ្នកបានមើលរឿងនោះដូចដែលយើងបានអានមកជាមួយ អ្នកនឹងឃើញវាកើតឡើងទៅកាន់រឿងដ៏ពិតនៃការនោះ។ ដូចនេះ ព្រះយេស៊ូពុំមានការហាមប្រាម ឬក៏អ្វីមួយឡើយ ទ្រង់គ្រាន់តែយាងទៅឆ្ងាយពីផ្ទះ ហើយយាងទៅកាន់កន្លែងណាមួយ ទ្រង់មិនបានយាងមកនៅពេលយប់នោះឡើយ។ ហើយទ្រង់បានយាងទៅកាន់ទីក្រុងមួយផ្សេងទៀត។ ហើយភ្លាមនោះពេលព្រះយេស៊ូបានយាងចេញពីផ្ទះ បន្ទាប់មកបញ្ហាក៏ចូលមកដល់។

66 ហើយ នៅពេលព្រះយេស៊ូយាងចេញពីផ្ទះរបស់អ្នក បញ្ហាគឺនឹងលេចចេញមក។ សូមចងចាំថា នៅពេលទ្រង់យាងចេញពីផ្ទះរបស់អ្នក បញ្ហាគឺនឹងកើតមានឡើង។ នៅពេលអ្នកចូលរួមនៅក្នុងសង្គម ហើយគ្រប់យ៉ាងកំពុងដំណើរការនៅក្នុងក្រុមជំនុំរបស់អ្នកយ៉ាងល្អ ដូចជាស៊ីឡាំងរីគិនប៉ែកឃើដប់ប្រាំមួយជ្រុងដ៏ធំអ៊ីចឹង ហើយអ្នកបានដាក់ព្រះយេស៊ូឲ្យនៅខាងក្រៅ នៅពេល ព្រះយេស៊ូបានយាងចេញពីក្រុមជំនុំរបស់អ្នក បញ្ហាក៏ធ្វើដំណើរមក។ ហ្នឹងហើយ នៅពេលព្រះយេស៊ូចាកចេញពីនិកាយ ពួកគេបានដាក់ទ្រង់នៅម្ខាងហើយនិយាយថា "ល្អ ឥឡូវយើងគ្រាន់តែកុំជឿរឿងទាំងនោះ វាអាចត្រូវពិត" ហើយអ្នកទទួលនៅអ្វីមួយផ្សេងទៀត បញ្ហានឹងលេចឡើង។ ចងចាំពីការនោះ។

67 រំលឹក ខ្ញុំពីរឿងរបស់ព្រះយេស៊ូ ដែលបានរកឃើញនៅក្នុងកណ្ឌគម្ពីរ លូកា។ អ្នកដឹងទេ កាលទ្រង់នៅវ័យ ប្រហែលជា១២ឆ្នាំ ប្រជាជនរបស់ទ្រង់ បាននាំទ្រង់

ទៅជាទម្លាប់សម្រាប់ឆ្នាំនីមួយៗទៅកាន់ពិធីបុណ្យថ្ងៃទីហាសិប។ ហើយ ខណៈពេលពួកគេនៅក្នុងទីក្រុងយេរូសាឡឹម នៅបុណ្យថ្ងៃទីហាសិប ហើយ នឹងមានពេលសប្បាយរីករាយ យើងបានឃើញរឿងនេះនៅក្នុងព្រះគម្ពីរ ដែលពួក គេបានចេញទៅបីថ្ងៃដោយពុំមានទ្រង់។ ហើយពួកគេបានគិតថាគ្រាន់តែទទួល យកវាដើម្បីទទួលបានផល ដែលព្រះយេស៊ូបានគង់នៅក្នុងចំណោមញាតិ សន្តានរបស់ពួកគេ។ ឥឡូវនេះ យើងមិនអាចធ្វើបែបនេះឡើយ។ នៅពេលពួកគេ មកជួបញាតិសន្តានរបស់ពួកគេ ដើម្បីជួប តែទ្រង់មិនគង់នៅទីនោះទេ។

68 ហើយ យើងមិនអាចអត់ទ្រាំនឹងទទួលយកការនេះបានទេ ដោយព្រោះ យើងជាពួកនិកាយប្រូតេស្តង់ បាទីស្ត ព្រីសប៊ីធើរៀន ហើយប្រវត្តិ របស់ពួកយើង ហើយបុព្វបុរសរបស់យើង គឺជាអ្នកមានជំនឿរឹងមាំ យើងគ្រាន់តែ ទទួលយកវា សម្រាប់ការល្អ ព្រះយេស៊ូគឺគង់នៅជាមួយយើង។ យើងមិនអាចធ្វើ បែបនោះទេ។ យើងត្រូវមានមានទំនាក់ទំនងជាមួយ ទ្រង់ជារៀង រាល់ថ្ងៃ នឹងគ្រប់នាទី។ អូ ខ្ញុំ ស្រឡាញ់ការនោះ។

69 ខ្ញុំ ចង់បានអ្វីដែលជាព្រះឥឡូវនេះ។ អ្វីដែលឪពុកម្តាយរបស់ខ្ញុំមាន អ្វីដែលបុព្វបុរសខ្ញុំមានគឺពិតជាអស្ចារ្យណាស់។ ប៉ុន្តែអ្វីពួកគាត់មានគឺពិត ជាល្អណាស់។ ខ្ញុំគិតថាយើងស្ថិតនៅលើផ្លូវដ៏ល្អប្រសើរ។

70 ចូរយើងមើលថាទ្រង់ជាអ្វីថ្ងៃនេះ។ ខ្ញុំមិនចង់ក្រឡេកមើលក្រោយ ហើយឃើញអ្វីដែលលោក ម៉ូឌី(Moody) បានធ្វើ ដោយព្រោះយើងបាន ស្ថិតនៅលើផ្លូវដ៏ល្អប្រសើរ ជាងលោក ម៉ូឌីហើយ។ បញ្ហាជាមួយនឹងក្រុមជំនុំរបស់យើង យើងក្រឡេកមើលទៅវិញ នឹងនិយាយថា "បាទ សូមមើលអ្វីដែលលោក ចន វេស្លី (John Wesley) បាននិយាយ តើមានអ្វីផ្សេងទៀតដែលអ្នកដទៃបាន និយាយ។" នោះគឺជាហេតុផលវិទ្យាសាស្ត្រ គឺស្ថិតនៅលើផ្លូវដ៏ប្រសើរនៅក្នុង វិស័យរបស់ពួកគេ ជាជាងវិស័យសាសនាទៅទៀត។

71 ទីនេះកាលបីរយឆ្នាំមុន អ្នកវិទ្យាសាស្ត្រជនជាតិបារាំងម្នាក់បាន បង្ហាញថាប្រសិនបើអ្នកទទួលបានល្បឿនរហូតដល់៣៥ម៉ាយក្នុងមួយម៉ោង កម្លាំងទំនាញនឹងទាញយកអ្នកចេញពីផែនដី។ អ្នកគិតថាវិទ្យាសាស្ត្រនឹងសំដៅ ទៅរកអតីតកាលនៅថ្ងៃនោះឬទេ? ពួកគេមានល្បឿនដល់ទៅ ១៩០០ម៉ាយ ក្នុងមួយម៉ោង ហើយនៅតែបន្តទៅមុខទៀត។ ពួកគេកំពុងតែរុញឆ្ពោះទៅមុខ កំពុងសម្លឹង

ទៅមុខ។ ប៉ុន្តែយើងចង់ក្រឡេកទៅមើលអតីតកាល ហើយឃើញពីអ្វីដែលលោក ម៉ូឌី លោក សានឃី (Sankey) លោក ហ្វីនី (Finney) ណក់ (Knox) ខាលវីន (Calvin) បាននិយាយពីអ្វីអស់ទាំងនោះ។ អ្វីដែលពួកគាត់បាននិយាយគឺពិតជាត្រឹមត្រូវ។ នោះគឺសម្រាប់អាយុកាលរបស់ពួកគេ ប៉ុន្តែយើងគឺកំពុងតែបន្ត។

72 លោកតារបស់ខ្ញុំ បានជិះនៅលើរទេះគោមួយ។ ខ្ញុំកំពុងតែបើកឡានហ្វដវី៨។ កូនប្រុសរបស់ខ្ញុំ នឹងបើកយន្តហោះប្រតិកម្ម។ នោះយើងកំពុងតែបន្តទៅមុខ។ នោះគឺជាអ្វីដែលសាសនាគួរតែបែបនោះ។ ការយាងមករបស់ព្រះជា ម្ចាស់គឺនៅជិតបង្កើយ។ ក្រុមជំនុំគួរតែឆ្ពោះទៅមុខដោយកម្លាំងរបស់ពួកគេ។ វិទ្យាសាស្ត្រអាចគ្រាន់តែឡើងខ្ពស់ប៉ុណ្ណឹង ហើយបន្ទាប់មកវាត្រូវធ្លាក់ចុះមកវិញ ប៉ុន្តែ យើងធនធានដែលមិនបានយកមកប្រើ ដែលមិនធ្លាប់បានប៉ះពាល់ នៃអំណាច ដោយមិនកំណត់នៃព្រះជាម្ចាស់ ដែលយើងគួរតែឆ្ពោះទៅមុខជាមួយ នឹងអំណាច នេះ។ យើងកំពុងតែរស់នៅរយៈចម្ងាយមួយលានម៉ាយ ក្រោមអភ័យឯកសិទ្ធិ របស់យើងនៅយប់នេះ ជាឯកសិទ្ធិនៃគ្រិស្តបរិស័ទ ដើម្បីសប្បាយរីករាយ។ ខ្ញុំមាន អារម្មណ៍អៀនខ្មាស់ដោយខ្លួនរបស់ខ្ញុំ នៅពេលខ្ញុំមើលនៅទីនេះ ហើយឃើញ ស្ថាប័នជាច្រើន ជំងឺ នឹងបញ្ហាជាច្រើនកំពុងមាននៅពេលនេះ។ ក្រុមជំនុំរបស់ យើងគួរតែដើរចេញទៅព្យាបាលអ្នកជំងឺ ប្រោសអ្នកស្លាប់ឲ្យរស់ឡើងវិញ បណ្តេញវិញ្ញាណអាក្រក់ បង្កើតសញ្ញា នឹង ការអស្ចារ្យ ធ្វើឲ្យពិភពលោកទាំងមូល ដឹងថាព្រះយេស៊ូគ្រិស្តមានព្រះជន្មគង់នៅ។ នោះហើយគឺជាអ្វីដែលយើងត្រូវតែ ធ្វើ។

73 ហេតុអ្វី អ្នកនិយាយថា "លោក ម៉ូឌីមិន..." លោកម៉ូឌី មិនបានរស់នៅសព្វថ្ងៃនេះទេ។ ត្រូវហើយ។ យើងកំពុងតែរស់នៅជាមួយនឹងការយាង មករបស់ព្រះជាម្ចាស់។ ហើយយើងគ្រាន់តែទទួលយកវាដើម្បីជាផលប្រយោជន៍ ដែលទ្រង់គឺជាគ្រួសាររបស់យើងដែរ។ ប៉ុន្តែថ្ងៃក្រោយមកទៀតនៅពេល ក្រុមជំទាស់បានស្វែងរកការពិតពីលោកហ្គ្រាហាំ (Graham) យើងបានរកឃើញថា គាត់គឺមិនបានជាប់សាច់ញាតិជាមួយយើងទេ។

74 តើកន្លែងណា អ្នកបានស្វែងរកគាត់ឃើញ? កន្លែងណា—កន្លែងដែលពួកគេបានរកឃើញព្រះយេស៊ូ? កន្លែងណាដែលពួកគេចាកចេញពីទ្រង់។ តើកន្លែងណាដែលពួកគេចាកចេញពីទ្រង់។ នៅឯពិធីបុណ្យថ្ងៃទីហាសិប។ តើនៅកន្លែងណាយើងចាកចេញពីព្រះយេស៊ូ តើកន្លែងណាជាក្រុមជំនុំ? នៅឯពិធីបុណ្យទីហា

សិប។ នៅពេលយើងចាកចេញឆ្ងាយពីពេលដ៏យូរលុងនោះនៃអំណាចពេនតេកុស្ត ហើយនឹងពិធីបុណ្យទីហាសិប យើងដើចេញពីព្រះយេស៊ូរួចទៅហើយ។ នោះជា ការពិតហើយសម្លាញ់។ យើងកំពុងតែរស់នៅក្រោមអភ័យឯកសិទ្ធិ របស់យើង។ ហ្នឹងហើយ។

75 ពួកគេ បានចាកចេញពីទ្រង់នៅឯបុណ្យថ្ងៃទីហាសិប ហើយវាគឺជាកន្លែងតែមួយគត់ដែល ពួកនិកាយប្រូតេស្តង់ បាទីស ប្រីសប៊ីធើរៀន និងពេនតេកុស្តដែលនឹងអាច រកទ្រង់ឃើញគឺត្រឡប់ទៅកន្លែង ដែលពួកគេចាកចេញពីទ្រង់វិញ។ តើសេចក្ដីអំណររបស់ព្រះព្រះជាម្ចាស់នៅឯណា? តើអំណាចរបស់ព្រះជាម្ចាស់នៅកន្លែងណា? ក្រុមជំនុំសួរនៅថ្ងៃនេះ "តើ—តើមានអ្វីបានកើតឡើងចំពោះព្រះនៅក្នុងប្រវត្តិសាស្ត្រ?" ទ្រង់គឺកំពុងតែរង់ចាំប្រជាជន របស់ទ្រង់ ដើម្បីហៅទ្រង់ឲ្យយាងមកដោយវិញ្ញាណ។ ប៉ុន្តែ...

76 យើងមិនបានធ្វើការនេះតាមរយៈនិកាយឡើយ។ យើងមិនអាចធ្វើវាក្រោមចិត្តសាស្ត្រឡើយ។ យើងមិនអាចធ្វើវាក្រោមនព្វន្តសាស្ត្រឡើយ ឬក៏យើងមិនអាច ធ្វើវាជាមួយនឹងចំនេះដឹងបានទេ។ យើងញែកខ្លួនរបស់យើង ញែកខ្លួនរបស់យើង។ យើងមិនបានញែកចេញទេ។ យើងគឺជាមនុស្សតែមួយនៅ ក្នុងព្រះយេស៊ូគ្រិស្ត។ យើងគឺតែមួយនៅក្នុងព្រះគ្រិស្ត ហើយការកំណត់របស់យើង នឹងមិនធ្លាប់ធ្វើការនេះឡើយ។ ការកំណត់លឿនយ៉ាងណា វាក៏មិនអាចធ្វើការនេះ បានដែរ។ ចំនេះដឹងរបស់យើង គឺជាឧបសគ្គដ៏ធំបំផុតនៃដំណឹងល្អដែលមាន គឺជាចំនេះដឹង។

77 អ្វីដែលយើងត្រូវការគឺមិនមែនជាចំនេះដឹងនោះទេ។ យើងត្រូវការអំណាចចេស្ដា ហើយនឹងការបង្ហាញ នៃព្រះដ៏បរិសុទ្ធមកវិញនៅក្នុងក្រុមជំនុំ ដើម្បីបង្ហាញពីអំណាចនេះ។ ព្រះយេស៊ូមិនធ្លាប់មានបន្ទូលថា "ចូរនាំគ្នាទៅគ្រប់ទីកន្លែងក្នុងពិភពលោក ហើយហើយបង្រៀន។" ទ្រង់មិនធ្លាប់មានបន្ទូលថា "ចូរនាំគ្នាទៅគ្រប់ ទីកន្លែងក្នុងពិភពលោក ហើយធ្វើ..." ទ្រង់មានបន្ទូលថា "ចូរនាំគ្នាទៅគ្រប់ទីកន្លែងក្នុងពិភពលោក ហើយប្រកាសដំណឹងល្អដល់មនុស្សលោកទាំងអស់ចុះ។" ហើយ ដំណឹងល្អគឺត្រូវតែបង្ហាញពីអំណាចនៃព្រះដ៏បរិសុទ្ធ គឺជាការប្រោសឲ្យរស់ឡើងវិញ។ យើងនៅតែស្ថិតនៅចម្ងាយមួយលានម៉ាយ ខ្លីជាងចម្ងាយនៃកន្លែងដែលយើងគួរនៅទៅទៀត។ សូមឲ្យយើងបន្តឆ្ពោះទៅមុខទៀត។ ចូរយើង

ត្រឡប់ទៅក្រោយវិញ ជាកន្លែងដែលយើងបានចាកចេញពីទ្រង់នៅឯពិធីបុណ្យ ទីហាសិប។

78 ព្រះយេស៊ូ បានមានបន្ទូលនៅក្នុងយ៉ូហានថា ខ្ញុំជឿ ជំពូកទី១៥ ទ្រង់បានមានបន្ទូលថា "ខ្ញុំហ្នឹងហើយជាដើមទំពាំងបាយជូរដ៏ពិតអ្នកគឺជាមែក។" ហើយ ឥឡូវនេះ ប្រសិនបើ ដើមទំពាំងបាយជូរនោះបានបង្កើតមែកជាលើកដំបូង ហើយមែកនោះបានសរសេរពីកណ្ឌគម្ពីរកិច្ចការ មែកទីពីនឹងសរសេរជាកណ្ឌកិច្ច ការមួយទៀត។ មែកទីបីនឹងសរសេរជាកណ្ឌកិច្ចការមួយទៀត។ ហើយគ្រប់មែកទាំងអស់ដែលបង្កើតចេញមកពីដើមទំពាំងបាយជូរ នឹងដូចគ្នាទៅនឹងមែកទីមួយដែរ។

79 ឥឡូវនេះ អ្នកអាចបំបៅខ្មែង យើងដឹងបែបនោះ។ ខ្ញុំធ្លាប់បានឃើញដើមឈើមួយរួមជាមួយនឹងផ្លែដែលមានប្រាំបីប្រភេទខុសៗគ្នានៅលើវា។ ខ្ញុំធ្លាប់បានឃើញដើមក្រូចមួយ មានផ្លែទំពាំងបាយជូរ ហើយមានផ្លែក្រូច ហើយនឹងផ្លែផ្សេងទៀតនៅលើវា ប៉ុន្តែវាបានប្រមូលផ្តុំតែមួយ។

80 នោះគឺ ជាអ្វីដែលជាបញ្ហានៅសព្វថ្ងៃនេះ។ យើងមានពង្រាងក្នុងគំនិតរបស់យើង ពង្រាងក្នុងនិកាយរបស់យើង ប៉ុន្តែប្រសិនបើដើមឈើនោះធ្លាប់បានបង្កើតផ្លែនៃដើមទំពាំងបាយជូរ ដោយខ្លួនវាផ្ទាល់ វាប្រហែលជាដូចទៅនឹងដើមឈើពីដំបូងដែលបានបង្កើតជាមួយវា។ ហាលេលូយ៉ា! អូ ក្រុមជំនុំនឹងលាយបញ្ចូលជាមួយគ្នា ប៉ុន្តែយើងត្រូវការអំណាចនៃប្រភពដើម។ យើងត្រូវការព្រះវិញ្ញាណបរិសុទ្ធ អំណាចនៃការរស់ឡើងវិញ នៃព្រះយេស៊ូគ្រិស្ត។ នោះគឺជាអ្វីដែលទ្រង់បានមានបន្ទូលប្រាប់យើងធ្វើ។

81 "ខ្ញុំ គឺជាដើមទំពាំងបាយជូរ អ្នកគឺជាមែក។" ប្រសិនបើដើមទំពាំងបាយជូរបង្កើតផលផ្លែជាមួយចង្កោម ហើយវាជាទំពាំងបាយជូរ ដែលមានពណ៌ខៀវដ៏ស្រស់ស្អាត ដើមទំពាំងបាយជូរមួយទៀតនឹងបង្កើតផលជាផ្លែទំពាំងបាយជូរដែល មាន ពណ៌ខៀវដ៏ស្រស់ស្អាតនៅលើដើមវា។ ប្រសិនបើដើមទំពាំង បាយជូរទីមួយបង្កើតផ្លែមក ហើយបានក្រោមការប៉ះពាល់ដោយ ព្រះវិញ្ញាណបរិសុទ្ធហើយពួកវាបានធ្វើការអស្ចារ្យ និងទីសម្គាល់ និងបោះត្រាលើទីបន្ទាល់ របស់ពួកវាទៅកាន់ពិភពលោក...ទោះបីពួកគេជាច្រើនមានទីបន្ទាល់ ជាមួយនឹងឈាមរបស់ពួកគេក៏ពួកគេបានបោះត្រាលើទីបន្ទាល់របស់ពួកវាដែរ។ ពួកគេបានឆ្លង

កាត់នូវគ្រោះថ្នាក់គ្រប់ប្រភេទក្នុងការនាំដំណឹងល្អ។ ពួកគេរងការឈឺចាប់ ពួកគេត្រូវបានជាន់ឈ្លី នឹងត្រូវបានគេ ដាក់ទោស។ "តើយើងត្រូវតែនាំយកផ្ទះទៅកាន់ស្ថានសួគ៌ដែលមានគ្រែគុបតែងស្អាត ខណៈពេលដែលអ្នកផ្សេងទៀតប្រកួតគ្នាដើម្បីរង្វាន់ និងការបើកក្ដោងឆ្លងកាត់សមុទ្រឈាម?" តើយើងគិតរំពឹងថានឹងធ្វើអ្វី? "ខ្ញុំត្រូវតែប្រយុទ្ធ ប្រសិនបើខ្ញុំត្រូវសោយរាជ្យ។ ព្រះជាម្ចាស់សូមបន្ថែមការលើកទឹកចិត្តដល់ខ្ញុំ។" ប្រាកដណាស់។ យើងពិតជាត្រូវការ...

82 យើងមិនត្រូវការនិកាយថ្មីឡើយ។ យើងមិនត្រូវការអាគារព្រះវិហារថ្មី ឡើយ។ អ្វីដែលយើងត្រូវការនៅថ្ងៃនេះ គឺជាពេលវេលាអតីតកាលសម័យកាលពីមុនផ្ទៃមេឃពណ៌ខៀវ អំពើបាបត្រូវសំលាប់ ការផុសផុលនៃពេនតេកុស្ត ដែលបានកើតឡើងនៅបុណ្យថ្ងៃទីហាសិបត្រឡប់មកកាន់ក្រុមជំនុំ វិញ អំណាចនៃព្រះវិញ្ញាណបរិសុទ្ធ ដើម្បីយាងព្រះយេស៊ូមក។

83 ជាព្រះនៃប្រវត្តិសាស្ត្រដែលតែងតែលេចឡើងក្នុងចលនាសំខាន់ៗ។ យើងត្រូវការវា។ នោះគឺជាបញ្ហានៅក្នុងក្រុមជំនុំរបស់យើង បច្ចុប្បន្ននេះ។ យើងកំពុងតែស្ថិតនៅឆ្ងាយ ពីអតីតកាលហើយ។ យើងកំពុងតែធ្លាក់ទៅក្នុងគំរូរបស់លោកីយ៍ហើយ។ ជាបណ្ដើរៗ ពីមួយឆ្នាំទៅមួយឆ្នាំ វាកំពុងស្លាប់ បន្តិចម្ដងៗ ហើយនឹងថយចុះទៅៗ។

84 វាគឺកំពុងធ្វើឲ្យពេលវេលាកាន់តែជិតមកដល់ឆាប់ៗ។ ព្រះជាម្ចាស់នឹងបន្ថយពេលវេលាយ៉ាងពិតប្រាកដ ពេលខ្ញុំកំពុងតែឈរនៅលើវិទិការ។ ព្រះជាម្ចាស់ នឹងកាត់មែករបស់ដើមឈើ ដើម្បីឲ្យវាបង្កើតផលផ្លែ។ ទ្រង់នឹងកាត់កិច្ចការលោកីយ៍ចេញនៅថ្ងៃណាមួយ។ ដូចជាការបាត់បង់អំណាច ផ្លូវដែលក្រុមជំនុំបានកាន់តាមនៅក្រោមឈ្មោះនៃសាសនា។

85 ហើយ យើងបានរកឃើញថា នៅពេលដែលព្រះយេស៊ូបាន ចាកចេញ ទៅសេចក្ដីស្លាប់បានចូលមកដល់។ ពេលព្រះយេស៊ូចាកចេញពីក្រុមជំនុំរបស់យើង អំណាច នៃព្រះវិញ្ញាណបរិសុទ្ធក៏ចាកចេញ ពីក្រុមជំនុំរបស់យើងដែរ ព្រះវិញ្ញាណបានចាប់ផ្ដើមថយចុះ—ហើយស្លាប់។ ហើយអស់មួយ រយៈ ពេលមកនឹងគ្មានអ្វីជាមួយនឹងព្រះវិញ្ញាណឡើយ។ ពេលនេះ នៅពេលព្រះយេស៊ូបានយាងចាកចេញទៅ សេចក្ដីស្លាប់បានចូលមកដល់។ អូ វាគឺជាពេល ដ៏កម្សត់ណាស់។

86 ហើយ ចំនាំថា ពួកគេបានងឿងឆ្ងល់ ហើយពួកគេបានអធិស្ឋានឲ្យ ព្រះយាង

មក ប៉ុន្តែទ្រង់មិនបានយាងមកទេ។ ពួកគេបានអធិស្ឋានទៅកាន់ទ្រង់ ម្តងទៀត ហើយទ្រង់មិនបានយាងមកទេ ប៉ុន្តែទ្រង់ជ្រាបពីកិច្ចការ ដែលទ្រង់នឹងធ្វើ។ ទ្រង់ជ្រាបនៅយប់នេះ ពីកិច្ចការដែលទ្រង់នឹងធ្វើ។ វាមិនបានបាត់ បង់ទៅជាមួយនឹងទ្រង់ឡើយៈ ទ្រង់ជ្រាបដឹងយ៉ាងពិតប្រាកដពីអ្វីដែលទ្រង់បានកំណត់ដើម្បីធ្វើ។ ទ្រង់នឹងលើកមនុស្សឡើងដូចដែលខ្ញុំកំពុងឈរនៅក្នុងព្រះវិហារនេះ។ ទ្រង់នឹងលើកមនុស្សឡើងដោយយល់ដល់ព្រះនាមទ្រង់ ចេញពីសាសន៍ដ៏ទៃ។ ទ្រង់នឹងធ្វើវា។

87 វាគឺជាពេលវេលារបស់សាសន៍យូដានៅជិតបង្ហើយឥឡូវនេះ ហើយនឹងជាពេលនៃសាសន៍ដ៏ទៃត្រូវបញ្ចប់ ពីព្រោះតែពួកគេបានអស់ពេលហើយ។ ពួកគេបដិសេធព្រះគ្រិស្ត ពួកគេបដិសេធសញ្ញារបស់ពួកគេ ពួកគេកំពុង បដិសេធអ្វីៗទាំងអស់ដែលត្រូវបានគេហៅថា ភាពជាព្រះ ហើយដាក់វាថាជាប្រភេទនៃចំណេះដឹង ឬជាអំណាចវិញ្ញាណអាក្រក់ ហើយធ្វើ...ពួកវាកំពុងតែ ប្រមាថព្រះដ៏បរិសុទ្ធ ហើយធ្វើឲ្យពួកគេស្ថិតនៅឆ្ងាយពីព្រះជាម្ចាស់។ ហើយព្រះ ជាម្ចាស់នឹងនាំយកចំនួនភាគតិចនោះអស់មួយរយៈពេលហើយលើកវា ឡើងវិញទៅក្នុងអំណាចនៃក្រុមជំនុំ ហើយបង្វែរព្រះវិញ្ញាណទៅកាន់ជន ជាតិយូដា ហើយនាំយកសាសន៍ដ៏ទៃត្រឡប់មកក្រុមជំនុំដើមវិញ។ ពិតជាបែបនោះ។ ទ្រង់គឺកំពុងតែធ្វើកិច្ចការនេះហើយ។ អូ ធ្វើដូចម្តេច យើងមកជិតចុងបញ្ចប់ហើយ។

88 ព្រះយេស៊ូ ទ្រង់ជ្រាប។ ហើយបន្ទាប់មកទ្រង់បានមានបន្ទូលថា "ឡាសារជាមិត្តសម្លាញ់របស់យើងសម្រាន្តលក់ទៅហើយ។"

89 ហេតុអ្វី ពួកសាវ័កគិតថាគាត់កំពុងសម្រាន្តតែបន្តិចទេ។ "ប្រសិនបើគាត់សម្រាន្តលក់ដូច្នេះ គាត់នឹងបានជាវិញមិនខាន។"

90 ល្អ ទ្រង់មានបន្ទូលនៅក្នុង...ពាក្យសម្តីរបស់ពួកគេ ដូច្នេះហើយពួកគេអាចនឹងយល់បានពីអ្វីដែលទ្រង់បានមានបន្ទូល "គាត់បានស្លាប់ទៅហើយ សម្រាប់ជាប្រយោជន៍ដល់អ្នករាល់គ្នា ខ្ញុំសប្បាយចិត្ត ដោយខ្ញុំមិនបាននៅទីនោះ។" ឃើញទេ? "សម្រាប់ជាប្រយោជន៍ដល់អ្នករាល់គ្នា ខ្ញុំសប្បាយចិត្ត ដោយខ្ញុំមិនបាននៅទីនោះ។" ពីព្រោះពួកគេនឹងសុំឲ្យទ្រង់—ព្យាបាល—ព្យាបាលគាត់ ប៉ុន្តែទ្រង់បាន ជ្រាបថា ទ្រង់មិនអាចធ្វើកិច្ចការនេះបានឡើយ ដោយព្រោះនិមិត្តគឺមិនទាន់មកដល់នៅឡើយទេ...បន្ទាប់ពីរយៈពេលបួនថ្ងៃមកទ្រង់បានជ្រាបថានោះគឺ ជា

ពេលវេលាដែលព្រះវរបិតាបានប្រាប់ទ្រង់។ អស្ចារ្យខ្លាំងណាស់ ទ្រង់បាន មានបន្ទូលនៅឯផ្នូរ "បពិត្រព្រះបិតា ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលទ្រង់ព្រះសណ្ដាប់ទូលបង្គំ។ ប៉ុន្តែ ទូលបង្គំទូលព្រះអង្គដូច្នេះ ដើម្បីអោយបណ្ដាជនដែលនៅជុំវិញទូលបង្គំជឿថា ព្រះអង្គពិតជាបានចាត់ទូលបង្គំអោយមកមែន។" ឃើញទេ? ទ្រង់បានជ្រាបពីកិច្ចការអ្វីដែលទ្រង់នឹងធ្វើ។ ទ្រង់បានមានបន្ទូលថា "ហើយខ្ញុំត្រូវតែទៅដាស់គាត់អោយភ្ញាក់ឡើងវិញ។"

91 ឥឡូវនេះ ខ្ញុំអាចស្រមៃបានថា ផ្ទះតូចគឺពិតជាដួលរលំ។ របររកស៊ីត្រូវបាត់បង់ទុក្ខសោក...អូ វាគឺជាការអស្ចារ្យ នៅពេលអ្នកមានទុក្ខលំបាក ឬក៏ មានចិត្តដ៏សោកសៅ ហើយបន្ទាប់មកព្រះយេស៊ូ បានលេចចេញមក នៅពេលនោះ តើពិតទេ? ខ្ញុំអាចស្រមៃឃើញថា នាងម៉ាថា ជាស្ត្រីតូចដ៏ស្រស់ ស្អាតម្នាក់ជាមួយនឹងស្បៃបាំងមុខរបស់នាង ហើយនាងតូចម៉ារី ហើយពួកគេ កំពុងតែកាន់គ្នាដោយនិយាយថា "តើយើងនឹងធ្វើដូចម្ដេច? ឪពុក នឹងម្ដាយរបស់យើងបានស្លាប់បាត់អស់ហើយ និងប្អូនប្រុសដ៏ជាទីស្រលាញ់របស់ យើងទៀត...ពេលនេះ យើងបានចាកចេញពីក្រុមជំនុំ ហើយពួកយើងបានដាច់ចេញពី ពួកគេ ហើយចេញមកដើម្បីដើរតាមព្រះយេស៊ូ នៃអ្នកស្រុកណាសារ៉ែត។ ហើយទ្រង់បានរុញយើងចេញទៅឆ្ងាយនឹងបានដាក់ចោលនៅកន្លែងណាមួយ។"

92 ខ្ញុំ អាចឮពីអ្នករិះគន់ចូលមក នឹងនិយាយថា "ហេ តើព្រះដែលជាអ្នកប្រោសឲ្យជា ដែលជាព្យាការីនៃស្រុកកាលីឡេគង់នៅឯណា? តើទ្រង់គង់នៅទីណាពេលនេះ? ឃើញទេ ពេលពិតប្រាកដមកដល់ឲ្យទ្រង់ធ្វើកិច្ចការនោះ តែទ្រង់បានយាងចេញទៅបាត់។" គឺបែបនេះហើយ។ ឃើញទេ ព្រះជាម្ចាស់គ្រាន់ តែសព្វព្រះទ័យធ្វើបែបនោះ ដោយគ្រាន់តែឲ្យមនុស្ស គ្រាន់តែឲ្យមនុស្សបង្ហាញ ពួកគេជាអ្វីហ្នឹងហើយ គ្រាន់តែសាកល្បងពួកគេ ដើម្បីឃើញថាតើពួកគេពិតជាអ្វី។ ទ្រង់បានប្រទានព្រះពរដល់ពួកគេ។ ទ្រង់លេចចេញមក ទ្រង់បង្ហាញអង្គទ្រង់ ណែនាំអង្គទ្រង់ទៅកាន់មនុស្ស គ្រាន់តែចង់ឃើញពីប្រតិកម្មតប របស់ពួកគេ គ្រាន់តែចង់ឃើញថាតើពួកគេនឹងធ្វើអ្វីអំពីការនេះ។

93 ឥឡូវនេះ យើងឃើញបន្ទាប់ពី—ពីរបីថ្ងៃ បួនថ្ងៃកន្លងផុតទៅ ឡាសារដ៏គួរ ឲ្យអាណិតបានស្លាប់ហើយ។ ពួកគេបានបញ្ចុះសពរបស់គាត់។ ថ្ងៃទីពីរ ថ្ងៃទីបី ថ្ងៃទីបួន...ពេលនេះតើមាននរណាម្នាក់ដឹងថា នឹងមានការស្អុយរលួយនៅរយៈ ពេលបី

ថ្ងៃទេៈ ទីមួយ ច្រមុះបានដាច់ចេញពីផ្ទៃមុខ។ ហើយបន្ទាប់មក ការស្អុយ រលួយបានចូលមក ដង្កូវចាប់ផ្តើមស៊ីរាងកាយ។ ពួកគេបានបញ្ចុះគាត់នៅក្នុងដី ដាក់ថ្មធំមួយនៅពីលើផ្នូរ ជាកន្លែងដែលពួកគេបានបញ្ចុះគាត់។ ហើយនៅ ពេលនោះក្មេងស្រីម្នាក់បានចេញមក នឹងលុតជង្គង់ចុះនៅឯផ្នូរហើយស្រែកយំ។

94 ហើយបន្ទាប់ពីមួយរយៈពេលមក ដំណឹងល្អបានផ្សាយទៅជុំវិញនោះ "ព្រះយេស៊ូបានយាងមកហើយ យើងបានឃើញ ទ្រង់កំពុង ធ្វើដំណើរទៅក្នុងទីក្រុង។" អូ ក្មេងស្រី ម៉ាថា ដែលបានឮពីការដូច្នោះ ប្រហែលជា ពន្យាពេលពីការនោះនាងបានបញ្ជាក់ ពីអ្វីដែលនាងបានឃើញ។ នៅទីនេះដែលនាងបានមក។ នាងកំពុងតែមកតាមផ្លូវរត់ចេញមកស្វែងរកមើល។ ខ្ញុំអាចឮពីពួកគេមួយ ចំនួននៅតាមផ្លូវ និយាយថា "បាទ ខ្ញុំគិតថាអ្នកពេញចិត្តហើយពេលនេះដែលសាសនារបស់អ្នកក្លែងក្លាយ។" នាង មិនបានអើពើ នឹងពួកគេឡើយ ហើយបានដើរចេញមកឆ្លងកាត់ពួកអ្នករិះគន់ទាំងអស់។ នាងបានដើរចុះមក រហូតទាល់តែនាងបានជួបទ្រង់ ប្រហែលជាកំពុងតែអង្គុយនៅកន្លែងកាច់ជ្រុង។

95 ពេលនេះ វាប្រហែលជា នាងត្រូវតែ...នាងត្រូវតែមានសិទ្ធិ ដើម្បីស្តីបន្ទោសទ្រង់ ហើយ—ហើយនិយាយសម្តីអាក្រក់ទៅកាន់ទ្រង់។ ហេតុអ្វីនាង មិនរត់ទៅហើយនិយាយថា "មើនេះនែក មើលនេះនែក មើល។ ទ្រង់គឺជាព្យាការី ជាកូនរបស់ព្រះជាម្ចាស់។ ហេតុអ្វីបានជាទ្រង់មិនយាងមក នៅពេលដែលយើង ហៅទ្រង់។ ហេតុអ្វីយើងកំពុងតែឃើញការដ៏ឆ្គួតនេះនៅក្នុងទីក្រុងនាពេលនេះ។ យើងបានចាកចេញពីព្រះវិហាររបស់យើង ដើម្បីដើរតាមទ្រង់។" ហាក់បីដូចជា នាងមានសិទ្ធិ។ ប៉ុន្តែអ្នកដឹងទេ ដូចជាអ្វីដែលខ្ញុំបានអធិប្បាយ*ជាកូនចៀម នឹងជាព្រាប* ប្រសិនបើយើងជាចៀម ជាចៀមអស់សិទ្ធិដែលទ្រង់មាន។ វាគឺជា សិទ្ធិដ៏ពិតប្រាកដ។ ទ្រង់មិនបានទទួលបានអ្វីទាំងអស់ ប៉ុន្តែជាចៀម ដូច្នេះហើយ ទ្រង់ត្រូវតែដកសិទ្ធិនោះ។ ហើយអ្នកត្រូវបានដកយកសិទ្ធិទាំងអស់ ដែលអ្នក ទទួលបានដើម្បីបម្រើព្រះ។ នោះពិតជាត្រូវណាស់។

96 ខ្ញុំ កំពុងតែនៅពីក្រោយស្ត្រីទាំងនេះ នៅតាមផ្លូវពួកគេកំពុងតែពាក់សម្លៀកបំពាក់ចាស់អ្នកដឹងទេ ហើយពួកគេបាននិយាយថា "ល្អ យើង—យើងជាជនជាតិអាមេរិក។ យើងអាចធ្វើអ្វីទាំងអស់ដែលយើងចង់ធ្វើ។"

97 ខ្ញុំ បាននិយាយថា "នោះគឺពិតជាត្រឹមត្រូវណាស់ប៉ុន្តែប្រសិនបើយើងជាចៀម

អ្នកនឹងបំពានសិទ្ធិរបស់អ្នកហើយ។" ការជក់បារី ហើយនៅតែបន្តធ្វើការ បែបនោះ នោះគឺជារឿងអាក្រក់បំផុត ដែលស្ត្រីម្នាក់បានធ្វើការនេះ។ នោះគឺពិតជា ត្រឹមត្រូវណាស់។

98 ស្ត្រីម្នាក់បាននិយាយមកកាន់ខ្ញុំថាដូចជាមិនយូរប៉ុន្មានទេ គាត់និយាយមកកាន់ខ្ញុំ "ប៉ុន្តែប្អូនប្រុសប្រាណហាំ ពួកគេមិនបានផលិតសម្លៀកបំពាក់ផ្សេងទៀតឡើយ។"

99 ខ្ញុំបាននិយាយថា "ប៉ុន្តែពួកគេនៅតែបន្តបង្កើតម៉ាស៊ីនដេរ ហើយនឹងលក់ផលិតផល។ គ្មានការដោះសារ សម្រាប់ការនោះឡើយ។" នោះគឺពិតជាត្រឹមត្រូវណាស់។

100 ចូរចាំថា ថ្ងៃមួយ អ្នកប្រហែលជាធ្វើល្អនៅទីនេះ ទៅកាន់ប្ដីរបស់អ្នក ប៉ុន្តែអ្នកនឹងឆ្លើយតបទៅនឹងការប្រព្រឹត្ត អំពើផិតក្បត់ដោយពិតប្រាកដណាស់: "អ្នកណាក៏ដោយ ដែលសម្លឹងមើលស្ត្រីនោះ ដើម្បីប្រាថ្នាចង់បាននាង បានប្រព្រឹត្តិអំពើផិតក្បត់ក្នុងចិត្តរបស់គេរួចទៅហើយ។"

101 តើមាន បញ្ហាអ្វីជាមួយនឹងស្ត្រីព្រះវិហារពេនតេកុស្តសព្វថ្ងៃ គឺជាអ្វីដែលខ្ញុំកំពុងតែឆ្ងល់។ តើអ្នកបានចេញឆ្ងាយពីខ្សែគន្លងនោះដោយរបៀបណា។ តើម្ដាយរបស់អ្នកធ្លាប់មានសក់វែង ដោយរបៀបណា ហើយថ្ងៃនេះស្ត្រីនៅពេនតេកុស្តបានតុបតែងខ្លួនដូចក្រុមម៉ាឌីក្រាស់ (Mardi Gras) ហើយកាត់ សក់របស់ពួកគេ ហើយពាក់សម្លៀកបំពាក់ចាស់តូចខ្លីមួយ ដូចបែបនោះ គ្រាន់តែ ដូចជាចំនែកសល់...ចេញក្រៅហើយកាត់ស្មៅនៅតាមទីធ្លានៅពេលរសៀល នៅពេលប្រុសៗដើរកាត់ តើអ្នកស្គាល់ស្ត្រី ដែលអ្នកនឹងឆ្លើយចំពោះការប្រព្រឹត្តិអំពើផិតជាមួយនឹងបុរសទាំងអស់នោះទេ? អ្នកតំណាងឲ្យខ្លួនឯងសម្រាប់បំណងបែបនោះ។ វាគឺជាវិញ្ញាណអាក្រក់នៅក្នុង ក្រុមជំនុំ ហើយនឹងនៅលើមនុស្ស ហើយពួកគេមិនបានដឹងពីការនេះទេ។ ពួកគេខ្វាក់ហើយមិនបានដឹងពីការនេះឡើយ។ វាគឺជាការពិត។

102 ប្រហែលជា អ្នកអាចនិយាយថា ខ្ញុំមិនមានសិទ្ធិក្នុងការនិយាយបែបនោះទេ ព្រោះខ្ញុំជាអ្នកផ្សាយដំណឹងល្អ។ បាទ ខ្ញុំខ្ញុំត្រូវតែដើរតាមការដឹកនាំរបស់ព្រះវិញ្ញាណបរិសុទ្ធ ទាំងអស់នោះហើយដែលខ្ញុំអាចនិយាយបាន។ អ្នក...ប្រសិនបើខ្ញុំជួបអ្នក នៅថ្ងៃជំនុំជំរះ ខ្ញុំមិនទទួលខុសត្រូវការស្លាប់របស់អ្នកឡើយ។ សូមចេញឲ្យឆ្ងាយពីដីដែលមើលទៅដូចជាសារតាំង។ សូមនៅឲ្យឆ្ងាយពីវា។ សូម

នៅឲ្យឆ្ងាយពីការនេះ។ ខ្ញុំមិនខ្វល់ថាតើ មានតារាទូរទស្សន៍ប៉ុន្មាន នាក់ទេ...អ្នក មិន បាននៅទីនេះទេ ជាតារាទូរទស្សន៍ម្នាក់ តែអ្នកគឺជាកូនស្រីរបស់ព្រះ។

103 បានអធិប្បាយ នៅក្នុងក្រុមជំនុំរបស់គ្រូគង្វាលម្នាក់នៅព្រឹកថ្ងៃបន្ទាប់ អំពីទាសករចំណាស់ម្នាក់ ជាពេលដែលគេលក់ពួកទាសករ ពីយូរ ណាស់មកហើយ។ ហើយពួកគេធ្លាប់បានមក ហើយទិញពួកគេនៅពេលដេញថ្លៃ។ ហើយប្រជាជនពួកគេកំពុងតែមានការឈឺចាប់ យំសោក ពីព្រោះតែទឹកដីកំណើតរបស់ពួកគេ ពួកគេមិនអាចត្រឡប់ទៅវិញបានទេ។ ហើយពួកគេត្រូវបានគេវាយ។ ហើយគេទិញ ពួកគេ ដូចជាអ្នកទិញរថយន្តមួយអញ្ចឹង សម្រាប់បម្រើការអ្វីមួយ តម្លៃ និងលក់ពួកគេដែល ជាមនុស្ស។

104 ហើយថ្ងៃមួយ អ្នកទិញម្នាក់បានមកជាមួយជើងសារចូលទៅកាន់កសិដ្ឋានធំមួយ...ចំម្ការធំជាងមួយ។ ហើយគាត់និយាយថា "តើអ្នកមានទាសករលក់ប៉ុន្មាននាក់?"

105 គាត់បាននិយាយថា "បាទ ខ្ញុំមានអ្នកខ្លះត្រូវដោះដូរ។" ពួកគេបានព្យាយាមឡើងថ្លៃ។ យកពួកគេជាម្ដាយ ជាឪពុក...ប្រសិនបើស្ត្រី ដែលគាត់ត្រូវរៀប ការជាមួយគឺជាស្ត្រីទន់ខ្សោយ សូមយកបុរសដែលមានសុខភាពល្អទាំងនេះ ហើយបន្តពូជជាមួយពួកគេទៅ...ដូចជាសត្វសេះនិងសត្វផ្សេងទៀត។ មិនមែន ជារឿងត្រឹមត្រូវទេ។ ព្រះជាម្ចាស់បានបង្កើតមនុស្ស។ មនុស្សបង្កើតទាសករ។ វាមិនមែនជារឿងត្រឹមត្រូវទេក្នុងការចាប់ផ្តើម មិនត្រូវសោះឡើយ។ ព្រះជាម្ចាស់មិនមានបំណងហប្ញទ័យឲ្យមនុស្សណាម្នាក់ ក្លាយជាទាសករឡើយ។ អត់ទេ លោក។ ហើយគ្មានទេ...ចូរមើលអ្វីដែលកើតមានឡើង។

106 បន្ទាប់មក នៅក្នុងចំណោមការទាំងនោះ បុរសម្នាក់នេះបាននិយាយថា "បាទ ខ្ញុំចង់ទិញពួកគេខ្លះ..." គាត់បានកត់សម្គាល់បុរសក្មេងម្នាក់នៅទីនោះ។ ពួកគេមិនចាំបាច់វាយគាត់ឡើយ។ ចង្ការរបស់គាត់ងើបឡើង ក្បាលងើបឡើង ដូចជាសុភាពបុរសម្នាក់អញ្ចឹង ដើរជុំវិញ ហើយអ្នកជើងសារនោះបាននិយាយថា "ខ្ញុំចង់ទិញគាត់។"

107 គាត់បាននិយាយថា "ប៉ុន្តែគាត់មិនមែនសម្រាប់លក់ទេ។"

108 គាត់បាននិយាយ "បាទ ហេតុអ្វី?" គាត់និយាយថា "តើគាត់ជាចៅ ហ្វាយនាយឬ?"

109 គាត់បាននិយាយថា "នេះ គាត់គឺជាទាសករ។"

110 "បាទ" គាត់បាននិយាយ "ហេតុអ្វី? តើអ្នកចិញ្ចឹមគាត់ល្អជាង អ្នកទាំងនោះឬ?"

111 គាត់និយាយ "ទេ គាត់បរិភោគនៅទីនោះ នៅក្នុងផ្ទះបាយជា មួយនឹងអ្នកទាំងនោះ។ គាត់គឺជាទាសករ។"

112 គាត់និយាយ "តើអ្វីដែលធ្វើឲ្យបុរសម្នាក់នោះ ខុសប្លែកពីអ្នកដទៃ?"

113 ហើយចៅហ្វាយនាយ បាននិយាយថា "ខ្ញុំក៏បានឆ្ងល់យូរ ណាស់មកហើយ ប៉ុន្តែថ្ងៃមួយខ្ញុំបានរកឃើញ។ នៅទឹកដីកំណើតគេ ឪពុករបស់ គាត់គឺជាស្តេចនៃកុលសម្ព័ន្ធ។ ហើយទោះបីកុលសម្ព័ន្ធរបស់គាត់ចេញឆ្ងាយពីផ្ទះក៏ដោយ គាត់នៅតែដឹងថាគាត់គឺជាកូនស្តេចមួយអង្គ ហើយគាត់បានធ្វើខ្លួនរបស់គាត់ ដូចជាស្តេចមួយអង្គ។" ប្រសិនបើការនោះ...ប្រសិនបើជនជាតិដើម អាមេរិកម្នាក់អាចទទួលថាឪពុករបស់គាត់គឺជាស្តេច ហើយនៅទីនេះមានសម្ព័ន្ធមិត្តម្នាក់ នៅលើទឹកដីចម្លែក នៅតែអាចដឹងថាឆ្លងកាត់សមុទ្រ គាត់គឺជាកូនស្តេច តើស្ត្រីនិងបុរស ទាំងអស់នោះគួរធ្វើខ្លួនយ៉ាងដូចម្តេចនៅពេលអ្នកជាកូនប្រុស នឹងកូនស្រីរបស់ព្រះជាម្ចាស់? គឺធ្វើបែបនោះ។ ពិតប្រាកដណាស់។ ធ្វើខ្លួនរបស់យើង ឲ្យល្អសម្អាតខ្លួនរបស់យើង ហើយធ្វើខ្លួនដូចជាកូនប្រុស នឹងកូនស្រីនៃព្រះជាម្ចាស់។ មិនថាជាលក្ខខណ្ឌអ្វីឡើយ។

114 យើងមកដល់នេះ។ អូ ក្មេងតូចម៉ាថា មកដោយការរត់។ នាងមើល ទៅដូចជានាង—មានមធ្យោបាយដើម្បីនិយាយអ្វីមួយប្រឆាំងនឹងទ្រង់។ "ហេតុអ្វីបាន ជាទ្រង់មិនមកជួបជាមួយនឹងប្អូនប្រុសខ្ញុំ? ចូរទតមើលពីអ្វីដែលពួកយើងធ្វើទៅកាន់ ទ្រង់ ហើយទ្រង់បានធ្វើឲ្យពួកយើងធ្លាក់ចុះ។" បាទ ប្រសិនបើនាងបាននិយាយបែបនោះ រឿងនេះនឹងមិនបញ្ចប់ឡើយ។ អត់ទេ។ វាគឺជាផ្លូវដែលអ្នកអាចខិតជិតទៅអំណោយទានភាពជាព្រះរបស់ព្រះជាម្ចាស់។ ប្រសិនបើ ព្រះជាម្ចាស់បានប្រទានអំណោយដល់អ្នក អ្នកត្រូវតែទទួលយកវា។ ប្រសិន បើអ្នកធ្លាប់រំពឹងថានឹងទទួលបានអ្វីមួយពីការនោះ អ្នកត្រូវតែខិតជិតទៅរបស់នោះ ត្រូវទេ។ ហើយម៉ាថា បានដឹងរួចហើយ។ នាងប្រហែលជា បានអាន អំពីស្ត្រីអភិជនម្នាក់ហើយនឹងកូនរបស់នាង។ ហើយនាង...ប្រសិនបើស្ត្រីអភិជន ម្នាក់នោះដឹងថា

ព្រះជាម្ចាស់គង់នៅជាមួយលោកអេលីយ៉ា តើទ្រង់គង់នៅជាមួយ នឹងព្រះយេស៊ូខ្លាំងយ៉ាងណាទៅទៀត? ប្រាកដណាស់។

115 ដូច្នេះហើយ នាងបានទៅជិតទ្រង់យ៉ាងត្រឹមត្រូវ។ នាងបានរត់មក ហើយក្រាបចុះនៅទាបបាទាទ្រង់។ ខ្ញុំពេញចិត្តនឹងការបែបនោះ! ក្រាបចុះនៅ ព្រះបាទារបស់ទ្រង់ ហើយនិយាយថា "ព្រះជាម្ចាស់..." នោះគឺជាគោរម្យនាមដ៏ ត្រឹមត្រូវរបស់ទ្រង់។ នោះហើយគឺជាអ្វី។ ទ្រង់គឺជាព្រះជាម្ចាស់របស់នាង។ "ព្រះជាម្ចាស់ ប្រសិនបើព្រះអង្គបានគង់នៅទីនេះ ប្អូនប្រុសរបស់ខ្ញុំនឹងមិនស្លាប់ឡើយ។"

116 អូ ខ្ញុំអើយ! អូ ខ្ញុំ អាចគ្រាន់តែស្រម៉ៃឃើញព្រះហឫទ័យដ៏អស្ចារ្យរបស់ ទ្រង់ដូចដែលទ្រង់បានមើលទៅកាន់ស្ត្រីស្អាតម្នាក់នោះ ទឹកភ្នែកបានធ្លាក់ចុះពីថ្ពាល់របស់នាង។ ហើយនិយាយថា "ព្រះជាម្ចាស់ ប្រសិនបើព្រះអង្គបានគង់នៅ ទីនេះ ប្អូនប្រុសរបស់ខ្ញុំនឹងមិនស្លាប់ឡើយ។" មើលអ្វីដែលនាងបាននិយាយ។ "ប៉ុន្តែ ទោះបីឥឡូវនេះព្រះអម្ចាស់ ទោះជាគាត់ស្លាប់ក៏ដោយ ទោះបីជាដង្កូវស៊ីរាងកាយរបស់គាត់ក៏ដោយ ទោះបីជាឥឡូវនេះបើទ្រង់សុំអ្វីពីព្រះជាម្ចាស់នោះព្រះអង្គនឹងប្រទានអោយមិនខាន។"

117 អូ នោះគឺជាការសម្គាត់។ អ្នកអាចនិយាយបានថា "ខ្ញុំបានឆ្លងកាត់គ្រប់មន្ទីពេទ្យ។ គ្រូពេទ្យបាននិយាយថាខ្ញុំនឹងត្រូវស្លាប់ ទោះបីជាពេលនេះ ព្រះជាម្ចាស់... ខ្ញុំបានពិការដោយសារលោកសន្លាក់ ខ្ញុំមិនអាចធ្វើចលនាបានទេ ទោះបីជាពេលនេះ ព្រះជាម្ចាស់..."

118 ក្មេងតូចម្នាក់នោះ មានទឹកដក់នៅ*ក្នុងក្បាល*ធំណាស់ កាលពីយប់មិញ។ គ្មានអ្វីដែលអ្នកធ្វើបានឡើយ។ វាបានរីករាលដាលឡើង ហើយបានប៉ះទង្គិចក្បាលរបស់កូនតូចនោះហើយបានស្លាប់ទៅ។ "ទោះបីជាឥឡូវនេះ ព្រះជាម្ចាស់..." ទ្រង់នៅតែជាព្រះជាម្ចាស់ដដែល។ ទ្រង់នៅតែជាព្រះអម្ចាស់ដដែល។ "ទោះបីជាឥឡូវនេះ ព្រះជាម្ចាស់..." ហើយទ្រង់គង់នៅខាងស្តាំព្រះហស្តរបស់ព្រះជាម្ចាស់ដ៏មានព្រះចេស្តា ធ្វើការសុំអត់ទោសគ្រប់រឿង យើងបានប្រកាសដែលទ្រង់បានធ្វើសម្រាប់យើង។

119 ឥឡូវ ខ្ញុំមានអារម្មណ៍ជាសាសនា។ ប្រាកដណាស់។ អ្នកនឹងហៅខ្ញុំថាជាអ្នកប្រមូលផ្តុំជំនឿដោយបរិសុទ្ធ ដូច្នេះហើយ អ្នកអាចចាប់ផ្តើម ហើយទទួលយកវាបានដែរ។

120 ដូច្នេះហើយ ព្រះអង្គអើយ "ទោះបីជាឥឡូវនេះ ព្រះអម្ចាស់ បើទ្រង់សុំអ្វីពីព្រះ ព្រះអង្គនឹងប្រទានអោយមិនខាន។"

121 ព្រះយេស៊ូមានបន្ទូលថា "អ្វីៗដែលអ្នករាល់គ្នាទូលសូមព្រះវរមិតាក្នុងនាមខ្ញុំ ខ្ញុំនឹងធ្វើកិច្ចការនោះជាមិនខាន។"

122 "ប៉ុន្តែ ឥឡូវនេះ នាងខ្ញុំដឹងថាបើលោកសុំអ្វីពីព្រះជាម្ចាស់ក៏ដោយ ព្រះអង្គមុខជានឹងប្រទានអោយមិនខាន។" អូ នោះប្រហែលជាអ្វីដែលបានផ្លាស់ប្តូរនៅក្នុងព្រះហឫទ័យដ៏អស្ចារ្យរបស់ទ្រង់។

123 ទ្រង់បានមានបន្ទូលថា "ប្អូននាងនឹងរស់ឡើងវិញ។"

124 នាងនិយាយថា "ចាស ព្រះអម្ចាស់។ ប្អូនរបស់ខ្ញុំនឹងមាន ជីវិតរស់ឡើងវិញ។ គាត់គឺជាក្មេងល្អ។ គាត់នឹងរស់ឡើងវិញនៅថ្ងៃចុងក្រោយបំផុត។" ពួកសាសន៍យូដាជឿលើការរស់ឡើងវិញនៅថ្ងៃចុងក្រោយ។ "ប្អូនរបស់ខ្ញុំនឹងមានជីវិតរស់ឡើងវិញនៅថ្ងៃចុងក្រោយ។"

125 មើលមកទ្រង់។ ទ្រង់បានរុញអង្គទ្រង់ទៅជិត។ ទ្រង់មានបន្ទូលថា "ខ្ញុំជាសេចក្ដីរស់ឡើងវិញនិងជាជីវិត។" អូ ខ្ញុំអើយ។ មិនមានមនុស្សណាម្នាក់ហ៊ាននិយាយបែបនេះឡើយពីមុន។ គ្មាននរណាម្នាក់អាចនិយាយពីការនេះបានទៀតទេ។ ទ្រង់តែមួយអង្គគត់ដែលមានបន្ទូលពីការនេះ។ព្រះជាម្ចាស់មានបន្ទូលថា "ខ្ញុំជាសេចក្ដីរស់ឡើងវិញនិងជាជីវិត។" "អ្នកណាជឿលើខ្ញុំ ទោះបីស្លាប់ទៅហើយក៏នឹងរស់ឡើងវិញដែរ។ ហើយអ្នកណាដែលរស់នៅនិងជឿលើខ្ញុំ នឹងមិនស្លាប់ឡើយ។ តើអ្នកជឿ ការនេះទេ?"

126 នាងនិយាយ "ត្រូវហើយព្រះអម្ចាស់។" អូ នាងបានដឹងហើយថា មានអ្វីមួយនឹងកើតឡើង។ ត្រូវតែកើតឡើង។

127 នៅពេល ជំនឿកើតចេញពីសេចក្ដីស្មោះត្រង់ នឹងបានជួបព្រះជាម្ចាស់បន្ទាប់មក រឿងនោះនឹងរួមបញ្ចូលគ្នាដូចការ*នោះ*។ មានអ្វីមួយត្រូវតែកើតឡើង។ ខ្ញុំសូម ផ្ដាំទៅបងប្អូនទាំងអស់នៅយប់នេះនៅក្នុងព្រះនាមព្រះយេស៊ូគ្រិស្ត សូមឲ្យជំនឿរបស់អ្នកភ្ជាប់ទំនាក់ទំនងជាមួយព្រះជាម្ចាស់ បែបដូចនោះ នៅក្នុងរយៈពេលពីរបីនាទី យើងនឹងមានបុណ្យថ្ងៃទីហាសិបម្តងទៀត។ ពួកគេនឹងរកការបំបែកការរីកផុសផុលនៅក្នុងទីក្រុងនេះ មិនមានសមត្ថកិច្ចគ្រប់គ្រាន់ក្នុងប្រទេស

នឹងបញ្ឈប់ពួកគេឡើយ។ ត្រូវហើយ។ នឹងមានការរីកផុសផុលឡើង។ "ទោះបី ឥឡូវនេះក៏ដោយព្រះអម្ចាស់អើយ..."

128 "បពិត្រព្រះជាម្ចាស់ យើងយល់ច្បាស់ហើយទុកចោលការ*នេះ* យើងបាន ធ្វើការ*នេះ* ហើយការ*នោះ*។" ខ្ញុំមិនខ្វល់ពីអ្វីដែលទ្រង់បានធ្វើទេ "ទោះបីជា ឥឡូវនេះ ព្រះអម្ចាស់..." គាត់កំពុងតែរង់ចាំទ្រង់ហៅគាត់ឲ្យចេញមកវិញ។ គាត់... "តើអ្នក ជឿការនេះទេ?" ប្រាកដណាស់។ ហ្នឹងហើយ។ "ទោះបីឥឡូវអ្វីដែលអ្នកសុំ ទ្រង់..."

129 "តើអ្នករាល់គ្នាយកសពទៅទុកនៅឯណា?" ឥឡូវទ្រង់យាងចុះទៅក្នុងផ្នូរ។ ទ្រង់គឺជាមនុស្ស ដែលអាចព្រះកន្សែងបាន ទ្រង់គឺជាព្រះដែលអាចប្រោសមនុស្ស ស្លាប់ឲ្យរស់ឡើងវិញបាន។

130 ទីនេះ កន្លងយូរមកហើយ ស្ត្រីម្នាក់ដែលជាកម្មសិទ្ធិរបស់មនុស្សមួយក្រុម...ខ្ញុំ មិនដែលធ្វើការនេះជាទម្លាប់ទេ ធ្វើវាឲ្យក្លាយជានិកាយទេ។ ប៉ុន្តែស្ត្រីម្នាក់ នេះ... ពួកគេមិនបានជឿថាព្រះយេស៊ូ គឺជាព្រះឡើយ។ ពួកគេបាននិយាយថា ទ្រង់គឺ គ្រាន់តែជាព្យាការីម្នាក់ប៉ុណ្ណោះ។ ឥឡូវនេះ ទ្រង់គឺជា...ប្រសិនបើ ទ្រង់គ្រាន់តែ ជាព្យាការីម្នាក់យើងគឺស្ថិតនៅក្នុងបាបហើយ។ ទ្រង់មិនមែន ជាព្រះអម្ចាស់ គ្មានអ្វី ជាងព្រះអម្ចាស់ឡើយ ឬក៏ជាអ្នកបោកប្រាស់នៃពិភពលោក ដែលធ្លាប់មាន។ នោះ គឺពិតជាត្រឹមត្រូវ។ ទ្រង់គឺមានភាព ជាងមនុស្សធម្មតា។ នាងនិយាយថា "ទ្រង់គឺ មិនមែនជាព្រះទេ។"

131 នេះគឺជាអ្វីដែលមានច្រើននៅក្នុងដំណឹងល្អក្នុងសង្គមសព្វថ្ងៃនេះ ព្យាយាម ធ្វើឲ្យព្រះយេស៊ូគ្រិស្ត ក្លាយទៅជាព្យាការីម្នាក់។ ហេតុអ្វី ទ្រង់គឺជាព្រះ នៃពួក ព្យាការីទាំងអស់។ ប្រាកដណាស់ទ្រង់គឺជាព្រះ។

132 នាង បាននិយាយថា "ខ្ញុំនឹងបញ្ជាក់ពីការនេះដោយព្រះគម្ពីររបស់អ្នក 'ទ្រង់គឺ គ្រាន់តែជាមនុស្សម្នាក់។'"

133 ខ្ញុំបាននិយាយថា "ទ្រង់បានធ្វើកិច្ចការនេះ។"

134 ហើយនាងនិយាយ "នៅពេលដែលទ្រង់បានយាងទៅដល់ផ្នូររបស់ ឡាសារ ព្រះគម្ពីរបានចែងថា 'ទ្រង់បានព្រះកន្សែង' ទ្រង់ជាមនុស្សធម្មតា ឬក៏ទ្រង់ មិនអាច ព្រះកន្សែងបាន។"

135 ខ្ញុំនិយាយថា "នាងអើយ នោះគឺជាបទគម្ពីររបស់នាងឬ?" ខ្ញុំមិនមែនមានន័យថាជាការប្រមាថដែលនិយាយពីការនេះឡើយ ប៉ុន្តែខ្ញុំនឹងប្រាប់ នាងពីអ្វីដែលខ្ញុំបានប្រាប់នាង។

136 នាងបាននិយាយថា "ហ្នឹងហើយ។"

137 ខ្ញុំ បាននិយាយថា "ប្រយោគនោះ គឺមានភាពខ្សោយជាងទឹកស៊ុប ដែលធ្វើពីសាច់មាន់ ដែលបានបង្អត់ឲ្យជិតស្លាប់ទៅទៀត។" ខ្ញុំបាននិយាយថា "អ្នក—អ្នកមិនមានអ្វី មួយដើម្បីជាជំហរឡើយ។"

138 នាងបាននិយាយថា "ហេតុអ្វីបានជាទ្រង់ព្រះកន្សែង។ នោះគឺបង្ហាញថាទ្រង់គឺជាមនុស្សធម្មតា។"

139 ខ្ញុំ បាននិយាយថា "ទ្រង់គឺទាំងពីរជាមនុស្សធម្មតា នឹងមានភាពជាព្រះផង។ ទ្រង់គឺជាព្រះដែលមានរូបរាងជាសាច់ឈាម។"

140 នាងបាននិយាយថា "អូ ដូចជាមិនជឿសោះ។"

141 ខ្ញុំនិយាយ "ទ្រង់បានយាងទៅផ្នូរ ហើយព្រះកន្សែង។ នោះជាការពិតហើយ ប៉ុន្តែនៅពេល ទ្រង់ងើបឡើង..." បទគម្ពីរ បានចែងថា "មិនបាច់មើលត្រង់ទៅទ្រង់ពេកទេ មិនមានភាពស្រស់ស្អាតណា ដែលយើងត្រូវការទ្រង់ឡើយ។" ប៉ុន្តែនៅពេលទ្រង់បានរុញខ្នងពួកគេបន្តិច ហើយមានបន្ទូលថា "ឡាសារអើយ ចេញមក" ហើយមនុស្សម្នាក់ដែលបានស្លាប់ អស់រយៈពេលបួនថ្ងៃ ហើយបានរលួយនៅក្នុងផ្នូរហើយគាត់បានចេញមក។ នោះលើសជាងមនុស្សទៅទៀត។ សូមបង្ហាញខ្ញុំ ដែលមនុស្សអាចធ្វើវាបាន? តើវាគឺជាអ្វី? ភាពពុករលួយស្គាល់ម្ចាស់របស់វា។ ជីវិតស្គាល់អ្នកបង្កើតវា។ មានអ្វីមួយត្រូវតែកើតមានឡើង។ ទ្រង់មានមានបន្ទូល ហើយមនុស្សម្នាក់ ដែលបានស្លាប់នៅ ក្នុងផ្នូរអស់រយៈពេលបួនថ្ងៃហើយ បានរស់ឡើងវិញ ហើយបានឈរនៅក្រោប បាទារបស់ទ្រង់ នឹងមានជីវិតរស់ឡើងវិញ។ ហាលេលូយ៉ា! នោះគឺជាព្រះអម្ចាស់ ស្ថិតនៅក្នុងបុត្រារបស់ទ្រង់។ ត្រូវហើយ។ នោះគឺជាអ្វី ដែលព្រះអម្ចាស់បាន បង្កើតដោយអង្គទ្រង់ ជ្រាបតាមរយៈបុត្រារបស់ទ្រង់។ នោះគឺជាបន្ទូលរបស់ ព្រះអម្ចាស់ មិនមែនជាសម្ដីរបស់មនុស្សឡើយ។

142 ទ្រង់គឺជាមនុស្ស នៅពេលទ្រង់បានទតមើលជុំវិញនៅក្បែរដើមឈើនោះ នៅ

ថ្ងៃនោះរកអ្វីមួយសម្រាប់សោយ។ នោះគឺជាមនុស្សម្នាក់។ ប៉ុន្តែ នៅពេលទ្រង់ បាន ទតមើល នំប្រាំដុំ នឹងត្រីពីរកន្ទុយ ហើយបានចំអែតមនុស្សប្រាំពាន់នាក់ នោះគឺជាភាពលើសជាងមនុស្ស។ នោះគឺជាព្រះដែលបានចំអែតពួកគេនៅទី នោះ។ ទ្រង់គឺមានភាពជាងព្យាការី ជាងមនុស្ស ទ្រង់គឺជា ព្រះមនុស្ស។ ពិតណាស់។

143 ទ្រង់បានដាក់ព្រះហស្តនៅពីក្រោយទូកតូចនោះនាពេលយប់នោះ ហើយទឹកសមុទ្រផ្គរលាន់ដ៏ខ្លាំងក្លាដូចជាដបបានផ្ទុះឡើងនៅទីនោះ នៅក្នុងសមុទ្រដ៏ធំនោះ នៅពេលខ្មាំងសត្រូវមួយម៉ឺននាក់គំហក់សមុទ្រឲ្យពន្លិចទ្រង់នៅ យប់នោះ។ ទ្រង់គឺជាមនុស្ស ខ្សោយនឹងអស់កម្លាំងពីការអធិស្ឋានសម្រាប់អ្នកជំងឺទ្រង់ផ្ទុំនៅទីនោះ ហើយសូម្បីតែ ខ្យល់ក៏មិនអាចរំខានដល់ទ្រង់ផងដែរ។ ទ្រង់គឺ ជាមនុស្ស នៅពេល ទ្រង់បានផ្ទុំលក់ ប៉ុន្តែ នៅពេលទ្រង់តើនឡើង ដាក់ព្រះបាទ របស់ទ្រង់នៅខ្សែរក្តោងទូក ទតមើល ហើយមានបន្ទូលថា "ស្ងប់ស្ងៀមទៅ" ហើយខ្យល់ព្យុះក៏ស្ងប់ ហើយផ្ទៃទឹកក៏រាបស្មើដែរនោះគឺជាងមនុស្សធម្មតាទៅទៀត។ នោះគឺជាព្រះអម្ចាស់គង់នៅក្នុងមនុស្ស ដែលធ្វើឲ្យទ្រង់ស្គាល់អង្គទ្រង់ ផ្ទាល់។ នោះគឺត្រូវហើយ។

144 ទ្រង់ គឺជាមនុស្សម្នាក់នៅឯឈើឆ្កាងនៅពេលទ្រង់ព្រះកន្សែងសម្រាប់ សេចក្តីមេត្តា។ នៅពេលទ្រង់ព្រះកន្សែង ហើយមានបន្ទូលថា "ខ្ញុំស្រេកឃ្លាន" នោះគឺជាមនុស្ស។ នៅពេលទ្រង់បានសុគត ទ្រង់គឺជាមនុស្ស ប៉ុន្តែ នៅព្រឹកថ្ងៃ បុណ្យរំលឹកព្រះគ្រិស្តមានព្រះជន្មរស់ឡើងវិញ នៅពេលទ្រង់បំបែកត្រានៃសេចក្តី ស្លាប់ស្ថាននរក ហើយនឹងផ្នូរ ហើយមានព្រះជន្មរស់ឡើងវិញ ទ្រង់គឺមានភាព ជាងមនុស្សទៅទៀត នោះគឺជាព្រះអម្ចាស់ធ្វើការបើកសម្តែង។ មិនថាមានសុភាសិតបានចែងឡើងថា

> រស់នៅទ្រង់ស្រលាញ់ខ្ញុំ សុគតទៅទ្រង់សង្គ្រោះខ្ញុំ
> បញ្ចុះទៅទ្រង់នាំបាបខ្ញុំចេញឆ្ងាយ
> រស់ឡើងវិញទ្រង់ប្រោសខ្ញុំឲ្យមានសេរីរៀងរហូត:
> ថ្ងៃមួយ ទ្រង់នឹងមកវិញ—អូ ថ្ងៃដ៏មានសិរីរុងរឿង!

145 ទ្រង់ មានបន្ទូលថា "ដោយព្រោះខ្ញុំរស់ អ្នកក៏មានជីវិតរស់ដែរ។ តើជឿការនេះដែរឬទេ?" ទ្រង់នៅដដែល ម្សិលមិញ ថ្ងៃនេះ និងរៀងរហូត។ តើអ្នកជឿការនេះឬទេ? ខ្ញុំជឿថាទ្រង់នឹងបំពេញ យើងដោយព្រះវត្តមានទ្រង់។ តើអ្នកជឿការនេះឬទេ? ខ្ញុំជឿលើព្រះវិញ្ញាណបរិសុទ្ធ ចង់ចាក់បង្ហូរព្រះវត្តមានទ្រង់មកព្យាបាល

អស់ទាំងជំងឺ ធ្វើឲ្យមនុស្សទាំងអស់ដែល មិនមានព្រះវិញ្ញាណបរិសុទ្ធត្រូវបានបំពេញ។ តើអ្នកជឿការនេះឬទេ? តើជឿដោយអស់ពីចិត្តរបស់អ្នកឬទេ? សូមក្រោកឈរឡើង ហើយថ្វាយការសរសើរដល់ទ្រង់។ ខ្ញុំជឿ ទ្រង់នឹងបំពេញ យើងព្រះវិញ្ញាណលើយើងនៅពេលនេះ។

146 អូ ព្រះអង្គជាម្ចាស់ ជាអាទិករបង្កើតផ្ទៃមេឃនឹងផែនដី ជាអង្គបង្កើតជីវិតទាំងអស់ "តើអ្នកជឿការនេះឬទេ" ព្រះអង្គ។ យើងជឿថា ទ្រង់គង់នៅទីនេះ នៅក្នុងការប្រជុំនេះ។ យើងជឿថាគឺទ្រង់ដែលបានប្រទានពរដល់ព្រលឹងវិញ្ញាណរបស់យើង។ យើងជឿថាគឺទ្រង់ដែលបានចាក់បង្ហូរព្រះវិញ្ញាណរបស់ទ្រង់លើយើង។ យើងជឿថា ទ្រង់ដូចកាលពី ម្សិលមិញ ថ្ងៃនេះ និងជារៀងរហូត។ យើងជឿថាទ្រង់មានព្រះជន្មគង់នៅអស់កល្បហើយឈ្មោះរបស់យើងត្រូវបានសរសេរនៅក្នុងក្រាំងគម្ពីរ ជីវិតនៃកូនចៀម។ គ្រប់ទាំងផ្ទៃមេឃនិងផែនដីនឹងរលាយបាត់ទៅតែយើងនឹង រស់នៅជារៀងរហូតដោយព្រោះទ្រង់រស់អស់កល្បជានិច្ច។ ព្រះអម្ចាស់ទ្រង់បានសន្យាមកកាន់យើង។ យើងជឿការនេះដោយអស់ពីចិត្តរបស់យើង។ គ្រប់ការទាំងអស់នៅក្នុងយើង យើងជឿ ព្រះអម្ចាស់។ ខ្ញុំស្រឡាញ់ទ្រង់ ខ្ញុំស្រឡាញ់ទ្រង់។

147 តើ អ្នកជឿលើទ្រង់ឬទេ? ខ្ញុំជឿលើព្រះវិញ្ញាណបរិសុទ្ធ។ មានអ្វីមួយបានស្ថិតមកលើយើង។ តើអ្នកជឿការនេះឬទេ? ខ្ញុំជឿថាទ្រង់ចង់ព្យាបាលគ្រប់ទាំង មនុស្សទាំងអស់នាពេលនេះ។ តើអ្នកជឿការនេះឬទេ? លើកដៃអ្នកឡើងទៅ កាន់ទ្រង់។ សូមក្រោកឈរឡើង។ តើអ្នកជឿការនេះឬទេ? ព្រះវិញ្ញាណបរិសុទ្ធគង់ នៅទីនេះ។ នេះគឺការនោះហើយ! ពេត្រុសនិយាយថា "នោះគឺការនោះ ហើយ។" នោះគឺជាការហ្នឹងហើយ ជាព្រះវិញ្ញាណបរិសុទ្ធ។

148 អូ ព្រះអម្ចាស់ ជាអាទិករបង្កើតផ្ទៃមេឃ នឹងផែនដី ផ្តល់នូវអំណាចរបស់ព្រះហើយព្រះប្រទានពរ ហើយភាពជាព្រះបានគង់នៅជាមួយនឹងមនុស្ស ហើយប្រទានពរដល់ចិត្តរបស់ពួកគេ ហើយសូមឲ្យពួកគេអាចមើលឃើញថាបុត្រមនុស្សគឺមានព្រះជន្មអស់កល្បជានិច្ច។ សូមទទួលយកការនេះ អូ ព្រះអម្ចាស់។ យើងសូមថ្វាយពួកគេទៅកាន់ទ្រង់ នៅក្នុងព្រះនាមព្រះយេស៊ូគ្រិស្ត ជាបុត្រារបស់ព្រះ។

149 តើមាននរណាម្នាក់ពុំទាន់ទទួលបានព្រះវិញ្ញាណបរិសុទ្ធទេ សូមលើកដៃអ្នកឡើង ហើយសូមអធិស្ឋានទៅកាន់ទ្រង់។ ខ្ញុំជឿថាទ្រង់នឹងចាក់បង្ហូរមកលើអ្នក។ សូមឲ្យនរណាម្នាក់ដាក់ដៃនៅលើពួកគេ។ នេះគឺដល់ពេលហើយ។ ហេតុអ្វី

យើង នៅរង់ចាំទៀត? គឺដល់ពេលហើយ។ នេះគឺជាពេលសម្រាប់បុណ្យថ្ងៃទីហាសិប កំពុងត្រឡប់ទៅកាន់ព្រះជាម្ចាស់វិញហើយ។ សូមទទួលយកជាមួយព្រះអម្ចាស់។ បុណ្យថ្ងៃទីហាសិប! សូមឲ្យចិត្តបានជំរុញដោយអំណាចនៃព្រះដ៏រស់។ សូមឲ្យព្រះវិញ្ញាណបរិសុទ្ធចូលមកកាន់អ្នក បំពេញព្រលឹងរបស់អ្នក។ ទ្រង់គង់នៅទីនេះពីយប់មួយទៅយប់មួយ គង់នៅទីនេះដើម្បី ព្យាបាលអ្នកជំងឺផ្ដល់ពន្លឺដល់អ្នកងងឹតតាមរយៈអំណាចដ៏អស្ចារ្យទ្រង់បញ្ជាក់ពីអង្គទ្រង់ជារៀងរហូត គឺនៅដដែល។ ហាលេលូយ៉ា!

150 សរសើរដម្កើងទ្រង់។ សូមលើកដៃរបស់អ្នកឡើង។ សូមបំភ្លេចពីកន្លែងដែល អ្នកនៅ គ្រាន់តែដឹងថាទ្រង់គង់នៅជាមួយអ្នក ហើយសេចក្ដីសប្បុរស សិរីរុងរឿង អំណាច ហើយនឹងសេចក្ដីមេត្តារបស់ទ្រង់ស្ថិតនៅរហូត។ ទ្រង់គង់នៅអស់កល្ប នឹងនៅដដែល។ សូមសរសើរដម្កើងព្រះនាមព្រះអម្ចាស់។ ហាលេលូយ៉ា! អូ សរសើរដម្កើងព្រះនាមដ៏វិសុទ្ធ។

151 អូ ទ្រង់ពិតជាអស្ចារ្យ ទ្រង់ពិតជាមានអំណាច។ តើមានប៉ុន្មានម្នាក់ ចង់ប្រគល់ ជីវិតរបស់អ្នកទៅកាន់ព្រះអម្ចាស់នាពេលនេះ ឥឡូវនេះ? សូមលើកដៃឡើង។ តើមានប៉ុន្មានម្នាក់ ចង់ ប្រគល់ជីវិតរបស់អ្នកទៅកាន់ ព្រះអម្ចាស់នាពេលនេះ ឥឡូវនេះ? គឺបែបនោះហើយ។ សូមលើកដៃរបស់អ្នក ឡើង។ សូមក្រឡេកមើលពិធីបុណ្យថ្ងៃទីហាសិប។ សូមមើលពីប្រជាជនរបស់ព្រះ។ ខ្ញុំនឹងលើកដៃរបស់ខ្ញុំ។ "ព្រះអង្គអើយទូលបង្គំនៅទីនេះ ចាត់ទូលបង្គំចុះ។" ព្រះអម្ចាស់សូមឲ្យទេវតាម្នាក់ជាមួយនឹងភ្លើងនៃអាសនៈ ហើយសូម បង្ហូរចេស្ដារបស់ទ្រង់មកកាន់ពួកយើង។ ព្រះជាម្ចាស់ សូមទទួលយកការនេះ ដោយបំពេញជាមួយនឹងព្រះវិញ្ញាណរបស់ទ្រង់ អូ ព្រះវរបិតា។ សូម សណ្ដាប់ការអធិស្ឋានរបស់យើង អូ ព្រះជាម្ចាស់។ សូមសណ្ដាប់ការអធិស្ឋាន របស់យើង ដូចជាជំនឿរបស់កូនក្មេងដែលមានជំហរ។ សរសើរដម្កើងព្រះ នាមទ្រង់។

152 អូ ដូចជារលកនៃសិរីរុងរឿងធ្លាក់ចុះមក អូ ទឹកសន្សើមនៃសេចក្ដីមេត្តាធ្លាក់ចុះ មក។ អូ សរសើរដម្កើងព្រះនាមព្រះជាម្ចាស់។ សូមឲ្យព្រលឹងរបស់យើងរង់ចាំ។ តើអ្នកជឿការនេះឬទេ? តើអ្នកជឿការនេះឬទេ? នេះគឺជាព្រះវិញ្ញាណបរិសុទ្ធដែល យាងមក។ នេះគឺជាអំណាចដែលមើលមិនឃើញ ដែលនាំយើងចូលទៅកាន់ អាណាចក្ររបស់ព្រះជាម្ចាស់ ជាព្រះពរនៃបុណ្យថ្ងៃទីហាសិប។

ត្រឡប់មកវិញហើយ។ អ្នករំពឹងថានឹងបានត្រឡប់វិញ។ អ្នកគឺជាមនុស្សដែលមាន តម្លៃ។ ព្រះជាម្ចាស់ចង់ឲ្យអ្នកញែកខ្លួនរបស់អ្នក។ ស្ត្រីទាំងអស់គ្នាអើយ សូមសម្អាតខ្លួន របស់អ្នក។ បុរសរាល់គ្នាអើយ សូមសម្អាតខ្លួនរបស់អ្នក។ សូមយើងត្រឡប់ទៅវិញ ទៅកាន់ព្រះជាម្ចាស់ ហើយបម្រើព្រះជាមួយនឹងចិត្តដ៏ស្អាតពិតប្រាកដមួយ។

153 សរសើរដម្កើង ព្រះជាម្ចាស់ ព្រះវិញ្ញាណបរិសុទ្ធគឺបានយាងចេញមក នៅក្នុងការប្រជុំ។ ធ្វើតាមអ្វីដែលអ្នកចង់ធ្វើ។ គ្រាន់តែសូមឲ្យព្រះ វិញ្ញាណបរិសុទ្ធធ្វើ ការនៅក្នុងអ្នក។ មិនមានអ្វីដែលខ្ញុំអាចនិយាយបានទេ។ ខ្ញុំគ្រាន់តែ មិនដឹងថាមានអ្វីនឹងនិយាយនៅពេលនេះ។ ព្រះវិញ្ញាណបរិសុទ្ធគឺគង់ នៅពាសពេញអាគារនេះ។ សរសើរដម្កើងព្រះនាមព្រះអម្ចាស់។ សូមសរសើរ ដម្កើងព្រះនាមព្រះជាម្ចាស់។ អូ ហាលេលូយ៉ា! ហាលេលូយ៉ា! សូមសរសើរ ដម្កើងព្រះនាមព្រះជាម្ចាស់។ សូមសរសើរ ដម្កើងព្រះនាមព្រះជាម្ចាស់។ ប្រកប ដោយភាពស្វារ្យ នឹងប្រកបដោយសិរីរុងរឿង...ពិតជាល្អ ពិតជាអស្ចារ្យ ការសរសើរដម្កើងភាពបរិសុទ្ធនៃព្រះជាម្ចាស់ នៅលើចំពោះមុខរបស់អ្នក ដោយព្រះវត្តមានរបស់ព្រះវិញ្ញាណបរិសុទ្ធគង់នៅទីនេះ ហើយបង្ហាញយើងនូវ សិរីរុងរឿងរបស់ទ្រង់ដោយរូបភាពជាច្រើន នៅក្នុងទម្រង់តែមួយ សរសើរដម្កើងព្រះនាមទ្រង់។

154 សូមបែរ ទៅខាងស្តាំនៅជុំវិញ ហើយចាប់ដៃជាមួយនរណាម្នាក់ និយាយថា "សរសើរដម្កើងព្រះអម្ចាស់ បងប្អូនប្រុស។ សរសើរដម្កើងព្រះជាម្ចាស់ បងប្អូន ស្រី។" សូមចូលទៅតាមកន្លែង ហើយសូមឲ្យព្រះអម្ចាស់ធ្វើឲ្យយើងមានអំណរឡើង។ សរសើរដម្កើងព្រះជាម្ចាស់។ ត្រូវហើយ។ គ្រប់គ្នាខាងមេតូឌីស្ត និងបាទីស្ត ប្រីសប៊ីធើរៀន ពេនតេកុស្ត និងសេវេនដេអេដវេនទីស្ត ឬក៏អ្នកជាអ្វីក៏ដោយសូមចាប់ដៃគ្នាទៅវិញទៅមក នៅក្នុងព្រះវត្តមានរបស់ព្រះជាអង្គម្ចាស់។ គឺបែបនោះហើយ។ អូ ហាលេលូយ៉ា! ហាលេលូយ៉ា! ហាលេលូយ៉ា! អូ ខ្ញុំពិតជាសប្បាយចិត្តណាស់ ខ្ញុំគឺម្នាក់នៅក្នុងចំណោមពួកគេ។ ខ្ញុំសប្បាយចិត្តណាស់។ អូ ទឹក ភ្នែកបានធ្លាក់ចុះមក ធ្លាក់ចុះមកយ៉ាងខ្លាំង។ សិរីរុងរឿង! សិរីភាពនៅក្នុងព្រះជាម្ចាស់ សរសើរដម្កើងព្រះនាមដ៏បរិសុទ្ធរបស់ទ្រង់...សរសើរដម្កើងព្រះនាមព្រះ ជាម្ចាស់។ អូ ហាលេលូយ៉ា! សរសើរដម្កើងព្រះអម្ចាស់។

155 អូ ខ្ញុំសប្បាយចិត្តពេលឃើញៈ មនុស្សចាប់ដៃគ្នាទៅវិញទៅមក ហើយ

បញ្ចេញពន្លឺលើមុខរបស់ពួកគេ។ ចេស្តារបស់ព្រះបានមានបន្ទូលថា "គឺ បែបនោះហើយ។ គឺបែបនោះហើយ យើងជាកូនរបស់ព្រះអម្ចាស់។ យើងគឺតែមួយនៅក្នុងក្រុមជំនុំដ៏អស្ចារ្យមួយនេះ តែមួយនៅក្នុងមនុស្សម្នាក់ដ៏អស្ចារ្យ នៅក្នុងព្រះយេស៊ូគ្រិស្ត ជាកូនក្រមុំរបស់ទ្រង់ ដែលប្រកបដោយសិរីរុងរឿង។" ការយាងមករបស់ព្រះជាម្ចាស់កាន់ តែជិតមកដល់នៅយប់នេះ។ ប្រជាជនរបស់ទ្រង់ប្រមូលផ្តុំគ្នាហើយស្រឡាញ់ខ្លួនរបស់ពួកគេ...ជាមួយនឹងសេចក្តីស្រឡាញ់ នឹងអំណាចនៃព្រះវត្តមានរបស់ទ្រង់។ អូ នេះគឺដូចជាស្ថានសួគ៌។ អូ បែបនេះ គឺល្អណាស់។ អាម៉ែន។ អូ សិរីរុងរឿងពិតជាអស្ចារ្យៈគ្រាន់តែថ្វាយបង្គំព្រះអង្គដោយវិញ្ញាណ នឹងអំណាច។ ជាពេលតែមួយ។ នោះគឺជាការបញ្ចប់...នឹង ចាប់ផ្តើម។

156 គឺគ្មាន...ខ្ញុំបានប្រាប់ទៅបងប្អូនគ្រប់គ្នា "បងប្អូនគ្រប់គ្នា គ្មានកន្លែងណានឹងឈប់បានឡើយ។" គ្មានកន្លែងណាមួយនៅទីនេះដែល...យើងមិនធ្លាប់ បានចាប់ផ្តើម ដូច្នេះហើយ យើងមិនបញ្ឈប់ឡើយ។ គ្រាន់តែ—គ្រាន់តែអស្ចារ្យ...តើមានប៉ុន្មានមានអារម្មណ៍ល្អពិត ដោយព្រះវត្តមានរបស់ព្រះជាម្ចាស់។ អូខ្ញុំអើយ វាគឺអស្ចារ្យណាស់ ព្រះវត្តមានព្រះជាម្ចាស់គង់នៅទីនេះ។

157 ឥឡូវនេះ ព្រះវត្តមានរបស់ព្រះជាម្ចាស់ គឺគង់នៅទីនេះដើម្បីព្យាបាលអ្នកជំងឺធ្វើឲ្យមនុស្សមានសុខភាពល្អ។ គ្រាន់តែជឿលើទ្រង់។ តើអ្នកជឿលើទ្រង់ទេ? បើយើងអាចជឿទ្រង់ គ្រប់អ្វីទាំងអស់អាចធ្វើបាន។ តើអ្នកជឿការនោះទេ? តើអ្នកជឿលើព្រះវត្តមានរបស់ព្រះជាម្ចាស់។

158 ឥឡូវនេះ ខណៈពេលដែលអ្នក...ឲ្យពេលខ្ញុំបន្តិច គ្រាន់តែពេលបន្តិច នាពេលនេះ ហើយសូមស្តាប់គ្រាន់តែមួយភ្លែតប៉ុណ្ណោះ។ សូមឲ្យខ្ញុំបញ្ជាក់ប្រាប់អ្នកថាព្រះវិញ្ញាណបរិសុទ្ធគង់នៅទីនេះ។ ចូរឲ្យខ្ញុំបង្ហាញអ្នកថាព្រះវិញ្ញាណបរិសុទ្ធគឺតែមួយអង្គដែលមានបន្ទូល តែមួយអង្គដែលធ្វើកិច្ចការទាំងអស់ អ្នកដឹងទេ។ តើមានប៉ុន្មាននាក់ មកទីនេះដោយមានជំងឺ។ សូមលើកដៃរបស់អ្នកឡើង។ អ្នកដែលមានជំងឺ...គឺមានមនុស្សច្រើនណាស់។

159 មានមនុស្សម្នាក់ឈរនៅទីនោះ។ តើអ្នកជឿទេលោក? មិនមានកាតអធិស្ឋានទេ ប៉ុន្តែតើអ្នកជឿថាព្រះអម្ចាស់អាចព្យាបាលអ្នកបាន? តើអ្នកជឿថា ទ្រង់អាចមានបន្ទូលប្រាប់ខ្ញុំពីបញ្ហារបស់អ្នក? វាគឺផ្ទៃករបស់អ្នក។ អ្នកត្រៀម សម្រាប់ការវះកាត់។ ត្រូវទេ។ ឈ្មោះរបស់អ្នកគឺ ខាតរ៉ាយ (Cartwright) ត្រូវទេ។ តើត្រូវ

ទេ? រាដៃរបស់អ្នកឡើង។ ល្អណាស់។ សូមត្រឡប់ទៅផ្ទះវិញ ហើយសូមឲ្យមានសុខភាពល្អ អ្នកនឹងមិន ត្រូវការវាទេ។ អ្នកជឿវាទេ?

160 មនុស្សម្នាក់នោះ កំពុងបីកូននៅក្នុងដៃរបស់គាត់ តើអ្នកជឿថាខ្ញុំ ជាអ្នកបម្រើព្រះទេ? តើអ្នកជឿថាការនេះគឺជាព្រះវិញ្ញាណបរិសុទ្ធទេ? ខ្ញុំមិនស្គាល់អ្នកទេមែនទេ? មិនដែលឃើញអ្នកនៅក្នុងជីវិតខ្ញុំឡើយ យើងគឺជាជនចម្លែកចពោះគ្នា។ តើអ្នកជឿថាព្រះវិញ្ញាណបរិសុទ្ធ អាចប្រាប់ខ្ញុំពីបញ្ហា ដែលកូននោះមានឬទេ? កូននេះមានជំងឺរលាក។ ត្រូវទេ។ តើត្រូវទេ? ប្រាកដណាស់។ អ្នកមិនបានមកពីទីនេះទេ។ ទេ។ អ្នកមានបញ្ហាក្រពះ អ្នកកំពុងតែឈឺចាប់ជាមួយនឹងខ្លួនរបស់អ្នក។ ត្រូវទេ អញ្ចឹងឬ? អ្នកគឺមកពីទីក្រុងកាន់សាស (Kansas City)។ ត្រូវទេ។ សូមត្រឡប់ទៅវិញ ព្រះយេស៊ូគ្រិស្តព្យាបាលអ្នក ហើយ។ ហាលេលូយ៉ា! អ្នកជឿទេ។ តើអ្នកជឿការនេះដោយអស់ពីចិត្តរបស់អ្នកទេ?

161 នៅទីនេះ ទេវតានៃព្រះជាម្ចាស់បានធ្វើចលនានៅពីលើស្ត្រីតូច—តូចនេះរាងចាស់បន្តិច កំពុងអង្គុយនៅទីនេះ ទទួលការឈឺចាប់ជាមួយនឹង រោគក្លន។ តើអ្នកជឿថាព្រះអម្ចាស់នឹងព្យាបាលអ្នកពីជំងឺក្លននោះទេ ប្អូនស្រី? អ្នក ដែលមានផ្កាពណ៌ក្រហមនៅលើមួកសូមលើកដៃរបស់អ្នកឡើង។ ល្អ ណាស់។ សូមត្រឡប់ទៅផ្ទះវិញ ហើយសូមជាសះស្បើយ។ អាម៉ែន។ អូ ការនេះគឺជាព្រះអម្ចាស់ គឺជាព្រះគ្រិស្ត ជាព្រះរាជបុត្រានៃព្រះអម្ចាស់។ ទ្រង់រស់ ពីសុគតឡើងវិញ។ ទ្រង់គឺគង់នៅទីនេះ។

162 ឥឡូវនេះ សូមដាក់ដៃរបស់អ្នក លើម្នាក់ផ្សេងទៀត ហើយគ្រាន់តែថ្វាយការអធិស្ឋានដ៏ល្អមួយ គ្រប់គ្នាទាំងអស់ ខណៈខ្ញុំសូមឲ្យម្នាក់មកទីនេះ។ សូមមកទីនេះ ប្អូនប្រុស។ ខណៈអ្នកដាក់ដៃលើមនុស្សម្នាក់ទៀត ដើម្បីបង្ហាញថាព្រះអម្ចាស់ព្យាបាលអ្នកដែរ ខ្ញុំមានប្អូនប្រុសម្នាក់ឈរនៅទីនេះ ដើម្បីថ្វាយការអធិស្ឋានដែរ។ (សូមដើរទៅមុខ។ ល្អណាស់) សូមសរសើរដម្កើងព្រះនាមព្រះជាម្ចាស់។

60-0402 តើអ្នកជឿការនេះដែរឬទេ?

សាលប្រជុំសាលាក្រុង

ទូលសា, អូកឡាហូម៉ា ស.ហ.រ

KHMER

©2019 VGR, ALL RIGHTS RESERVED

VOICE OF GOD RECORDINGS

P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.

www.branham.org

## សេចក្តីជូនដំណឹងស្តីពីការរក្សាសិទ្ធិ

រក្សា រ សិទ្ធ គ្រប់យ៉ាង។ សៀវភៅនេះអាចត្រូវបានបោះពុម្ពនៅលើម៉ាស៊ីនបោះពុម្ពនៅផ្ទះសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ឬត្រូវបានផ្តល់ឱ្យដោយឥតគិតថ្លៃ ជាឧបករណ៍សម្រាប់ផ្សព្វផ្សាយដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ។ សៀវភៅនេះមិនអាចលក់ផលិតឡើងវិញក្នុងទ្រង់ទ្រាយធំ បង្ហោះនៅលើគេហទំព័រ រក្សាទុកក្នុងប្រព័ន្ធទាញយកមកវិញ បកប្រែជាភាសាផ្សេងទៀត ឬប្រើសម្រាប់ការស្នើសុំមូលនិធិដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី Voice Of God Recordings®។

សម្រាប់ព័ត៌មានបន្ថែម ឬសម្រាប់សម្ភារៈផ្សេងទៀត សូមទាក់ទង:

Voice Of God Recordings
P.O. Box 950, Jeffersonville, Indiana 47131 U.S.A.
www.branham.org